ដឹងអំពីជម្រើសរបស់អ្នក៖
កូនសៀវភៅសម្រាប់អ្នកស្វែងរកសិទ្ធិជ្រកកោននិងជនភៀសខ្លួននៅក្នុងប្រទេសថៃ

asylum access
THAILAND
Making Human Rights a Reality for Refugees

# ដឹងអំពី ជម្រើស របស់អ្នក

កូនសៀវភៅសម្រាប់អ្នកស្វែងរកសិទ្ធិជ្រកកោននិងជនភៀសខ្លួននៅក្នុងប្រទេសថៃ។



រក្សាសិទ្ធិសិទ្ធិគ្រប់យ៉ាងដោយ អង្គការអាសាយឡាំអាកសេសថៃឡែនដ៍,
ឆ្នាំ ២០១៩

# អំពីសិទ្ធិជ្រកកោនប្រទេសថៃ

## តើពួកយើងជានរណា ?

បានបង្កើតឡើងក្នុងឆ្នាំ ២០០៧, អង្គការ អាសាយឡាំអាកសេសថៃឡេនដ៏ ( AAT ) គឺជាអង្គការក្រៅរដ្ឋាភិបាលមួយ និងជាផ្នែកមួយនៃដំណើរការគ្រួសារនៃជនភៀសខ្លួន។ ពួកយើងប្រឹងប្រែងដើម្បីធ្វើឱ្យសិទ្ធិមនុស្ស ក្លាយជាការពិតសម្រាប់ជនភៀសខ្លួន។ ពួកយើងជឿជាក់ថាជនភៀសខ្លួនទាំងអស់សមនឹងទទួលបាននូវឱកាសត្រឹមត្រូវមួយក្នុងជីវិតថ្មី។ ដោយសារជនភៀសខ្លួនភាគច្រើន មិនអាចវិលត្រឡប់ទៅផ្ទះវិញបាន ហើយភាគតិចណាស់ ដែលបានតាំងទីលំនៅថ្មី។ ពួកយើងស្វែងបានរកវិធីសាស្រ្ត ដើម្បីជួយសម្រួលដល់ការរស់នៅរបសជនភៀសខ្លួនអោយប្រកបដោយសុវត្ថិភាព, ដើរហើរដោយសេរី, អាចធ្វើការបាន និងបានចូលរៀនក្នុងកំឡុងពេលដែលពួកគេរស់នៅទីនេះ ព្រោះនៅពេលជនភៀសខ្លួន អាចចាប់ផ្តើមកសាងជីវិតពួកគេបាន, នោះសហគមន៍ក៏រីកចម្រើនតាមហ្នឹងដែរ។

## តើពួកយើងធ្វើអ្វីខ្លះ ?

### ជំនួយផ្នែកច្បាប់

ក្រុមមេធាវីរបស់យើងនឹងផ្តល់ការប្រឹក្សាផ្នែកច្បាប់ដោយផ្ទាល់ និងជាតំណាងដល់ជនភៀសខ្លួនដែលស្វែងរកសិទ្ធិជ្រកកោន តាមរយៈនីតិវិធីនៃការកំណត់អត្តសញ្ញាណជាជនភៀសខ្លួនរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន និងសេវាការពារផ្សេងៗដល់ជនភៀសខ្លួន។ យើងក៏ផ្តល់ជូននូវសិក្ខាសាលាផ្នែកច្បាប់ ស្តីពីនីតិវិធីនៃការកំណត់អត្តសញ្ញាណជាជនភៀសខ្លួន ( RSD ) និងពិនិត្យលើគម្រោងជំនួយផ្នែកច្បាប់តាមសហគមន៍ ( Community Paralegal program ) ដើម្បីកសាងសមត្ថភាពជនភៀសខ្លួន។

### ការផ្តល់សិទ្ធិអំណាចផ្នែកច្បាប់ដល់សហគមន៍ ( **CLE** )

ក្រុមរបស់យើង ( CLE ) ធ្វើសកម្មភាពពង្រឹងអំណាចផ្នែកច្បាប់តាមសហគមន៍ ដើម្បីបង្កើនសមត្ថភាពជនភៀសខ្លួន។សកម្មភាពការងាររបស់ពួកយើងរួមមាន សកម្មភាពនៃការចាត់ចែងទៅលើ ក្រុមសម្ព័ន្ធភាពប្រជាធិបតេយ្យ, ការផ្តល់ជំនួយបញ្ហាសង្គមកិច្ចតាមសហគមន៍ និងការផ្តល់ជំនួយជាលក្ខណៈមិត្តភាព ដើម្បីបង្កើនឱកាសក្នុងការចិញ្ចឹមជីវិត និងការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីប្រធានបទ ដឹងពីជម្រើសរបស់អ្នក។

### គោលនយោបាយតស៊ូមតិ

យើងតស៊ូមតិ ដើម្បីការផ្លាស់ប្តូរបែបវិជ្ជមាន និងការអភិវឌ្ឍគោលនយោបាយផ្សេងៗ និងក្របខ័ណ្ឌច្បាប់ដើម្បីកាត់បន្ថយឧបសគ្គ ដែលរារាំងជនភៀសខ្លួនពីការរស់នៅដោយសុវត្ថិភាព និងការដើរហើរដោយសេរី។តាមរយៈការចូលរួមរបស់ភាគីពាក់ព័ន្ធ, ក្រុមការងាររបស់ពួកយើងធ្វើការជាមួយរដ្ឋាភិបាលថៃ, ទីភ្នាក់ងារអង្គការសហប្រជាជាតិ, អង្គការសង្គមស៊ីវិល, បណ្តាញតាមមូលដ្ឋាន និងអន្តរជាតិ, និងជនភៀសខ្លួនផ្ទាល់ ដើម្បីកែលម្អនូវទស្សនៈវិស័យផ្សេងៗដល់ជនភៀសខ្លួន។ការដាក់ពាក្យប្តឹងជាយុទ្ធសាស្រ្ត ដែលយើងធ្វើដើម្បីបង្កើតនូវ គំរូច្បាប់សម្រាប់សិទ្ធរបស់ជនភៀសខ្លួន តាមរយៈការសាកល្បងនៅក្នុងតុលាការ។ ទីបំផុត, យើងមានគោលដៅ ដើម្បីកាត់បន្ថយតម្រូវការជំនួយផ្នែកច្បាប់ ដោយធ្វើឱ្យសិទ្ធិជនភៀសខ្លួនក្លាយជាបទដ្ឋានទូទៅ, ដូច្នេះជនភៀសខ្លួនអាចទទួលបានសិទ្ធិរបស់ពួកគេ ដោយស្វ័យប្រវត្តិដោយមិនចាំបាច់តស៊ូដើម្បីរឿងនោះទៀតទេ។


ទំនាក់ទំនងពួកយើង

១១១១ / ១៥១ បានក្លាងមឿង,
ទូរស័ព្ទ៖ ( +៦៦ ) ២៥១៣ ៥២២៨

អ៊ីមែល: thailand@asylumaccess.org

# មាតិកា


១. បច្ចុប្បន្នភាពនៃស្ថាភាពជនភៀសខ្លួនក្នុងប្រទេសថៃ ១

២. កង្វល់នៃបញ្ហាអន្តោប្រវេសន៍ ការការពារ និងបញ្ហាសុវត្ថិភាព ៣

៣. ការការពារ និងសុវត្ថិភាព ១០

៤. ក្រុមគ្រួសារ និងជិវភាពប្រចាំថ្ងៃ ១៤

៥. ការអប់រំ ២០

៦. អ្វីគួរធ្វើ និងអ្វីដែលមិនគួរធ្វើ ២៦


## ការបដិសេធ

កូនសៀវភៅ KYO ត្រូវបានបង្កើតឡើងដោយ AAT។
ខ្លឹមសារនៃកូនសៀវភៅមិនមែនផ្តល់ជាដំបូន្មានផ្នែកច្បាប់ និងមិនគួររំពឹងលើវាខ្លាំងពេកទេ។

វាគ្រាន់តែជាការជួយផ្តល់នូវព័ត៌មានទូទៅជាលក្ខណៈសង្ខេបមួយបង្ហាញពីស្ថានភាពដែលកំពុងតែកើតឡើងក្នុងពេលបច្ចុប្បន្ន។ ព័ត៌មានដែលមាននៅក្នុងកូនសៀវភៅ KYO មួយក្បាលនេះទើបតែបានដាក់ផ្សព្វផ្សាយនៅថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០១៩។ រាល់ព័ត៌មានទាំងអស់នឹងអាចមានការកែប្រែ។

សូមទាក់ទងដោយផ្ទាល់មកកាន់ AAT បើសិនជាអ្នកមានចម្ងល់ណាមួយ



ឧបត្ថម្ភដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក

# ១

# បច្ចុប្បន្នភាពនៃស្ថានភាពជនភៀសខ្លួន ក្នុងប្រទេសថៃ

asylum access THAILAND

# បច្ចុប្បន្នភាពនៃស្ថានភាពជនភៀសខ្លួនក្នុងប្រទេសថៃ

ប្រទេសថៃជាជម្រករបស់ជនភៀសខ្លួនប្រមាណជា ៤៣០០ នាក់ និងអ្នកស្វែងរកសិទ្ធិជ្រកកោន ៨៥០ នាក់ ដែលរត់ភៀសខ្លួនគេចចេញពីជម្លោះប្រដាប់អាវុធ និងការធ្វើទុក្ខបុកម្នេញនៅក្នុងប្រទេសដើមកំណើតរបស់ពួកគេ។ ប្រទេសដើមកំណើតរបស់ពួកគេរួមមាន ប៉ាគីស្ថាន, ស្រីលង្កា, វៀតណាម, កម្ពុជា, សូម៉ាលៀ, ប៉ាឡេស្ទាញ, ស៊ីរី និងចិន។

ទោះបីជាប្រទេសថៃមិនមែនជាប្រទេសហត្ថលេខីនៃអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ ក៏ដោយ ក៏ប្រទេសថៃបានព្យាយាមបោះជំហានឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើងនៃការការពារ និងអោយមានដំណោះស្រាយសម្រាប់ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោននៅក្នុងប្រទេសថៃដែរ។ ទោះយ៉ាងណាក៏ដោយ, បទបញ្ញត្តិ និងគោលនយោបាយទាំងនោះ គឺស្ថិតនៅក្នុងដំណើរការវិនិច្ឆ័យនៅឡើយ ហើយផលប៉ះពាល់របស់វាចំពោះជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន នៅក្នុងប្រទេសថៃនៅតែមិនមានភាពច្បាស់លាស់នៅឡើយ។

## ការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត

ការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្តគឺជាដំណើរការនៃការវិលត្រឡប់ទៅផ្ទះដោយផ្អែកលើជំនួយប្រចិត្តរបស់បុគ្គលម្នាក់ៗ ដោយមានជំនួយពីអង្គការ UNHCR និង IOM សម្រាប់ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន ដែលកំពុងស្ថិតនៅក្នុងដំណើរការរបស់ពួកគេ។

IOM UN MIGRATION

IOM អាចជួយដលម្ចាសម្ចាស់សំណុំរឿង ដែលត្រូវបានបិទរួចមកហើយនោះ ដើម្បីអោយវិលត្រឡប់ទៅផ្ទះវិញបាន តាមរយៈជំនួយរបស់ពួកគេក្នុងការស្ម័គ្រចិត្តវិលត្រលប់វិញ

និងគម្រោងសមាហរណកម្មស្ម័គ្រចិត្ត (AVRR)។ AVRR អាចនឹងត្រូវចំណាយពេលច្រើនខែ។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង អង្គការ IOM ដោយមធ្យោបាយដូចខាងក្រោម៖ ( ទូរស័ព្ទ៖ +៦៦ ) ២-៣៤៣-៩៣០០ អ៊ីម៉ែល៖ iomthailand@iom.int

UNHCR The UN Refugee Agency

សម្រាប់ជនភៀសខ្លួន ដែលត្រូវបានគេទទួលស្គាល់ ឬអ្នកស្វែងរកសិទ្ធិជ្រកកោន នៅក្នុងដំណើរការ RSD, គួរតែត្រូវទាក់ទងទៅកាន់ អង្គការ UNHCR ទាក់ទិននឹងការវិលត្រឡប់ទៅវិញដោយស្ម័គ្រចិត្ត។

អង្គការ UNHCR ដោយមានកិច្ចសហការជាមួយអង្គការ IOM តាមរយៈកម្មវិធី AVRR, ប្រហែលជាអាចជួយសម្រួលដល់អង្គការ UNHCR ដោះស្រាយពីការព្រួយបារម្ភរបស់កូនក្តី ( ទាំងជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន ) ។ ប្រសិនបើអ្នកមានបំណងចង់ធ្វើមាតុភូមិនិវត្តន៍ ឬចង់ទទួលបានព័ត៌មានបន្ថែម សូមទាក់ទង UNHCR ដើម្បីសុំធ្វើការណាត់ជួបតាមរយៈមធ្យោបាយទំនាក់ទំនងដូចខាងក្រោម៖ លេខទូរស័ព្ទការិយាល័យ UNHCR:

( +៦៦ ) ២-២៨៨-២៣៣០ ឬ( +៦៦ ) ២-២៨៨-២៥២៩ ( ម៉ោងធ្វើការ ០៨:០០ នាទីព្រឹក ដល់

*ទិន្នន័យបានទាញយកពីការប្រជុំ BASRAN ខែកញ្ញា ឆ្នាំ ២០១៩

# ២

# ការព្រួយបារម្ភពីបញ្ហាអន្តោប្រវេសន៍

# ការព្រួយបារម្ភពីបញ្ហាអន្តោប្រវេសន៍

## A ទិដ្ឋាការនិងច្បាប់



### ១. ហេតុអ្វីបានជាយើងត្រូវបានចាប់ខ្លួនពីបទបំពានច្បាប់អន្តោប្រវេសន៍ ទាំងដែលយើងជាអ្នកស្វែងរកសិទ្ធិជ្រកកោន / ជាជនភៀសខ្លួនដែរនោះ ?

- តាមច្បាប់របស់ប្រទេសថៃ, ប្រសិនបើអ្នកចូលទៅក្នុងប្រទេសថៃដោយគ្មានឯកសារពេញលេញតាមច្បាប់ បូលិខិតអនុញ្ញាតិត្រឹមត្រូវ និងមិនបានចូលតាម ច្រកកុងត្រូល៍ទេនោះ, អ្នកនឹងត្រូវបានចាត់ទុកថាបានចូលទៅក្នុងប្រទេសថៃដោយខុសច្បាប់។
- ប្រសិនបើ អ្នកទទួលបានទិដ្ឋការទៅប្រទេសថៃ ប៉ុន្តែនៅតែបន្តនៅក្នុងប្រទេសថៃ បន្ទាប់ពីទិដ្ឋាការរបស់អ្នកផុតកំណត់ទៅហើយនោះ, អ្នកត្រូវបានគេចាត់ទុកថាជា មនុស្សស្នាក់នៅក្នុងប្រទេសដោយខុសច្បាប់ និងហួសទិដ្ឋាការ ហើយអាចនឹងត្រូវឃុំខ្លួនបុនិរទេសត្រលប់ទៅវិញ។ នៅក្នុងប្រទេសថៃ មិនមានច្បាប់ណាមួយបែងចែកអោយឃើញនូវភាពខុសគ្នារវាងជនភៀសខ្លួន និងជនចំណាកស្រុកផ្សេងទៀតដែលរស់នៅលើសទិដ្ឋាការព្រោះប្រទេសថៃមិនមែនជាប្រទេសហត្ថលេខីនៃអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ ឡើយ។



### ២. តើខ្ញុំអាចមានការប្រុងប្រយ័ត្នអ្វីខ្លះ នៅពេលខ្ញុំនៅប្រទេសថៃហើយមានការព្រួយបារម្ភទាក់ទងនឹងបញ្ហាអន្តោប្រវេសន៍

- យោងតាមច្បាប់របស់ប្រទេសថៃ អ្នកត្រូវ តម្រូវឲ្យ រក្សានូវអត្តសញ្ញាណប័ណ្ណជាប់ជាមួយអ្នកនៅគ្រប់ទីកន្លែងទាំងអស់ ដែលអ្នកមិននៅផ្ទះ រួមទាំងការជួលផ្ទះនិងទាក់ទងម្ចាស់ផ្ទះជាដើម។
- សូមចងចាំថាអាជ្ញាធរថៃ រួមមាន ប៉ូលីស, មន្ត្រីអន្តោប្រវេសន៍ ឬទាហាន សុទ្ធតែមានសិទ្ធិស្នើសុំពិនិត្យ អត្តសញ្ញាណប័ណ្ណរបស់អ្នកនៅគ្រប់ពេលទាំងអស់។
- ថតចម្លងលិខិតឆ្លងដែន និងឯកសារសំខាន់ៗ ហើយរក្សាទុកវានៅកន្លែងផ្សេងៗ និងជាប់តាមខ្លួនអ្នក។

### ៣. តើខ្ញុំអាចបន្តទិដ្ឋាការរបស់ខ្ញុំដោយស្របច្បាប់បានយ៉ាងដូចម្តេច ?



- អ្នកត្រូវចាកចេញពីប្រទេសថៃ ដើម្បីស្នើសុំទិដ្ឋាការថ្មីជាលក្ខណ: ទេសចរណ៍ ឬទិដ្ឋាការសិក្សារៀនសូត្រជាដើម។
- ដំណើរការនៃការបន្តទិដ្ឋាការដោយស្របច្បាប់គឺ អាស្រ័យទៅលើប្រភេទទិដ្ឋាការដែលអ្នកមាន។ អ្នកអាចរកព័ត៌មានបន្ថែមជាភាសាអង់គ្លេស ឬភាសាថៃបាននៅគេហទំព័ររបស់ក្រសួងការបរទេស http://www.mfa.go.th ឬ http://www.thaiimmigration.net/

### ៤. តើមានហានិភ័យអ្វីខ្លះទាក់ទងនឹងបញ្ហាទិដ្ឋាការក្នុងប្រទេសថៃ

#### ប្រើភ្នាក់ងារផ្សេងៗ

- អ្នកដែលអះអាងថា ពួកគេអាចធ្វើទិដ្ឋាការអោយអ្នកបាន យើងហៅពួកគេថាជាភ្នាក់ងារ។ ទាំងនេះភាគច្រើនជាភ្នាក់ងារទេសចរណ៍ឯករាជ្យ ឬអ្នកដែលទាក់ទងនឹងទិដ្ឋាការខុសច្បាប់។ សូមចងចាំថា:
  - ភ្នាក់ងារដែលធានាសុវត្ថិភាពទិដ្ឋាការនោះ ច្រើនតែលួចគេមក ឬក្លែងក្លាយ។
  - ភ្នាក់ងារអាចនឹងអះអាងថាពួកគេ មិនបានដឹងថាទិដ្ឋាការនេះក្លែងក្លាយ, ទុកអោយអ្នកទទួលខុសត្រូវចំពោះ ការចំណាយពីការក្លែងបន្លំ។

asylum access THAILAND

- ប្រសិនបើអ្នកបានទទួល និងមានបំណងចង់ប្រើនូវទិដ្ឋាការក្លែងក្លាយ ឬបានលួចមកនោះ, វាជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវជាប់ពន្ធនាគាររហូតដល់ ១០ ឆ្នាំ។ អ្នកក៏អាចនឹងត្រូវប្រឈមមុខនឹងការចាប់បញ្ជូនទៅវិញ ឬត្រូវឃុំខ្លួនផងដែរ។ សូមកត់សម្គាល់ថាអង្គការ UNHCR មិនអាចជួយអ្នកក្នុងដំណើរក៏ព្រហ្មទណ្ឌបានទេ។
- ភ្នាក់ងារផ្សេងៗទាំងនោះ គិតថ្លៃទិដ្ឋាការខ្ពស់ជាងរដ្ឋាភិបាល។

## ការគ្មានទិដ្ឋាការ

- អ្នកនឹងត្រូវបានគេចាត់ទុកថាបុគ្គលខុសច្បាប់នៅក្នុងប្រទេសថៃ និងមានហានិភ័យនៃការចាប់ខ្លួននិងឃុំខ្លួន។
- អ្នកមិនអាចដើរហើរបានដោយសេរីដោយគ្មានទិដ្ឋាការនោះទេ។ អ្នកអាចមានលទ្ធភាពទទួលសេវាកម្មជាលក្ខណៈមូលដ្ឋានដូចជា ការជួលផ្ទះស្នាក់អាស្រ័យ, មានកម្រិត។

## ប្រសិនបើអ្នកត្រូវបានស្នើសុំឱ្យបង់ប្រាក់ពិន័យដល់តុលាការ ហើយអ្នកមិនមានលទ្ធភាពបង់នៅពេលនោះ

- ការចរចារអំពីចំនួនទឹកប្រាក់គឺជា រឿងធម្មតាប៉ុន្តែប្រសិនបើ មើលទៅវាហាក់ដូចជាមិនអាចចរចារបាន, សូមសួរគេថាតើយើងអាចទូរស័ព្ទទៅមិត្តភក្តិ ឬក្រុមគ្រួសារ ឬ អង្គការ AAT ដើម្បីជួយយើងបានដែរទេ។
- អ្នកអាចនឹងត្រូវជាប់ពន្ធនាគារ - ពេលវេលានៃការសម្រុះសម្រួលសម្រាប់តុលាការ ដែលមិនបានបង់ប្រាក់គឺ ៥០០ បាតក្នុងមួយថ្ងៃ។
- បន្ទាប់ពីការសម្រុះសម្រួលហើយនោះ, អ្នកនឹងត្រូវផ្ទេរទៅមជ្ឈមណ្ឌលឃុំឃាំងជនអន្តោប្រវេសន៍ (IDC) ។

# ការចាប់ខ្លួន និងការឆ្មក់ចាប់

### តើនឹងមានអ្វីកើតឡើងប្រសិនបើខ្ញុំ ត្រូវបានចាប់ខ្លួន តើខ្ញុំអាចឆ្លើយតបយ៉ាងដូចម្តេច ហើយខ្ញុំអាចរំពឹងអ្វីបានខ្លះ ?

បង្ហាញកាត UNHCR របស់អ្នក ហើយទំនាក់ទំនងទៅលេខទូរស័ព្ទទាន់ហេតុការណ៍របស់ UNHCR

- អង្គការ UNHCR ប្រហែលជាអាចចរចារអោយមានការដោះលែងអ្នកបាន។
- ប្រសិនបើអ្នក ត្រូវបានគេនាំទៅកាន់ស្ថានីយប៉ូលីស អ្នកនឹងត្រូវគេសួរព័ត៌មានទូទៅអំពីខ្លួនអ្នក បន្ទាប់មកនឹងត្រូវគេចោទប្រកាន់ពីបទ មិនមានទិដ្ឋាការ/ ឬមិនមានលិខិតឆ្លងដែន។
- អ្នកនឹងត្រូវបានបញ្ចូលក្នុងបញ្ជីខ្មៅដោយខាងអន្តោប្រវេសន៍ថៃ ហើយមិនត្រូវបានអនុញ្ញាតឱ្យចូលប្រទេសនេះក្នុងរយៈពេល ៥ ឆ្នាំ។ សម្រាប់ករណីរស់នៅហួសកំណត់, អ្នកនឹងត្រូវបានដាក់ក្នុងបញ្ជីខ្មៅរយៈពេល ១០ ឆ្នាំ។
- សំណុំរឿងរបស់អ្នកនឹងត្រូវបញ្ជូនទៅតុលាការ ហើយអ្នកនឹងត្រូវបានស្នើសុំឱ្យបង់ប្រាក់ទៅតុលាការ។
- នៅពេលដែលអ្នកត្រូវបានចាប់ខ្លួន អ្នកក៏អាចនឹងត្រូវនាំទៅកន្លែងឃុំឃាំងជនអន្តោប្រវេសន៍ផងដែរ។ ក្នុងករណីណាក៏ដោយ សូមសហការណ៍ និងសុភាពរាបសាជាមួយអាជ្ញាធរ (មិនត្រឹមតែប៉ូលីសប៉ុណ្ណោះទេ, ពួកគេអាចនឹងមកពីក្រសួងមហាផ្ទៃ ឬក៏ជាកងទ័ព) ។



### តើនឹងមានអ្វីកើតឡើង ប្រសិនបើមានការលបឆ្មក់ចាប់របស់ប៉ូលីសនៅអាគារផ្ទះរបស់ខ្ញុំ ?

- ជាធម្មតាការឆ្មក់ចាប់តាមផ្ទះល្វែងគឺមានទ្រង់ទ្រាយធំ ហើយមនុស្សជាច្រើនអាចនឹងត្រូវចាប់ខ្លួនក្នុងពេលតែមួយជាមួយគ្នា។
- គួរមានមនុស្សម្នាក់ទូរស័ព្ទទៅលេខហតឡាញរបស់អង្គការ UNHCR ហើយរាយការណ៍អំពីអាស័យដ្ឋាននៃអាគារនោះ ហើយបើសិនអាចធ្វើបាន គួរប្រាប់ថាតើមានមនុស្សប៉ុន្មាននាក់ពាក់ព័ន្ធ ពួកគេទាំងអស់ជាជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន ឬចម្រុះទាំងអស់គ្នា។
- ប្រសិនបើអង្គការ UNHCR មិនអាចទាក់ទងបាន, អ្នកក៏អាចទូរស័ព្ទទៅអង្គការបម្រើជលជនភៀសខ្លួនរួមទាំង អង្គការ AAT ផងដែរ។

- ក្នុងករណីមានអាសន្ន សូមទាក់ទងមកខ្សែ ទូរស័ព្ទទាន់ហេតុការណ៍ UNHCR តាមរយៈលេខ (+៦៦) ៨១-៨៩៩-៧៦១៧ (ចាប់ពីម៉ោង ១៦:៣០ នាទី ដល់ ម៉ោង២៣:០០នាទីយប់ សម្រាប់ថ្ងៃធ្វើការធម្មតា និងចាប់ពីម៉ោង០៨:៣០ នាទីព្រឹក ដល់ម៉ោង ២៣:០០នាទីយប់
- ប្រសិនបើអ្នកមិនអាចទាក់ទងមន្ត្រី UNHCR បានទេនោះ, សូមព្យាយាមទាក់ទងអង្គការបម្រើជនភៀសខ្លួនផ្សេងៗទៀតដូចជា អង្គការ Asylum Access Thailand (AAT) ជាដើម។

# ការព្រួយបារម្ភពីដំណោះស្រាយដ៏យូរអង្វែងរបស់ UNHCR

### សំណុំរឿងរបស់ខ្ញុំត្រូវបានបិទ ហើយខ្ញុំចាប់អារម្មណ៍ចង់វិលត្រឡប់ទៅប្រទេសរបស់ខ្ញុំវិញ (ការវិលត្រឡប់ដោយស្ម័គ្រចិត្ត)

### តើខ្ញុំអាចទាក់ទងអ្នកណាបាន ?

អ្នកអាចទាក់ទងអង្គការខាងក្រោម ដើម្បីសួរព័ត៌មានបន្ថែមអំពីការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត៖

IOM អង្គការអន្តោប្រវេសន៍អន្តរជាតិ *

ជាន់ទី ១៨, អាគារ រ៉ាឆាណាកាណ ៣, មហាវិថីហ្សាថនខាងត្បូង, ទីក្រុងបាងកក, ១០២១០,
ម៉ោងធ្វើការ៖ ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពីម៉ោង ០៨ព្រឹក ដល់ ម៉ោង ០៥ល្ងាច។
ទំនាក់ទំនងទូរស័ព្ទលេខ៖
(+៦៦) ២-៣៤៣-៩៣០០

អ៊ីម៉េល៖ iomthailand@iom.int

ប្រសិនបើអ្នកនៅក្នុង អាយឌីស៊ី សូមទំនាក់ទំនង មន្ត្រីយូអិន ដែលបម្រើការនៅក្នុងអាយឌីស៊ី។

### ខ្ញុំនៅតែរង់ចាំការតាំងទីលំនៅថ្មី។

- សូមចងចាំថា ការមានឋានៈជាជនភៀសខ្លួន មិនមែនមានន័យថាអ្នកពិតនឹងត្រូវតាំងទីលំនៅថ្មីនោះទេ។ សូមយល់ថា ការតាំង ទីលំនៅថ្មី មិនមែនជាសិទ្ធិ ឬជាការធានាសម្រាប់ជនភៀសខ្លួនទាំងអស់នោះទេ។ នៅទូទាំងពិភពលោក, ជារៀងរាល់ឆ្នាំមានជនភៀសខ្លួនតិចជាង ១ ភាគរយទៅទៀត ដែលត្រូវបានតាំងទីលំនៅថ្មី។ ឱកាសនៃការតាំងទីលំនៅថ្មីសម្រាប់ជនភៀសខ្លួនក្នុងទីក្រុងនៅ នៅក្នុងប្រទេសថៃ គឺនៅមានកម្រិតនៅឡើយ។ ការទទួលបានឋានៈ ជាជនភៀសខ្លួន មិនបានធានាដល់ការតាំងទីលំនៅថ្មី ឬការពិចារណាសម្រាប់ការតាំងទីលំនៅថ្មីនោះទេ។ ការដែលត្រូវបានពិចារណាគឺ មិនមែនចាំបាច់ត្រូវឱ្យមានការតាំងទីលំនៅថ្មីនោះទេ។ អង្គការ UNHCR នឹងទាក់ទងទៅអ្នក ប្រសិនបើអ្នកត្រូវបានគេពិចារណាសម្រាប់ការតាំងទីលំនៅថ្មី។

- ប្រសិនបើសំណុំរឿងរបស់អ្នកត្រូវបានបញ្ជូនចេញដើម្បីបានតាំងទីលំនៅថ្មីតាមរយៈអង្គការ UNHCR, ការពិចារណាថាបាន ឬមិនបាននោះគឺអាស្រ័យលើប្រទេសដែលគេបានផ្ញើរសំណុំរឿងទៅនោះឯង។ដើម្បីសុំការទីលំនៅថ្មីនោះឯង។

### តើអង្គការ UNHCR ជួយសម្រួលដល់ការធានាឯកជនដែរទេ ?

- UNHCR, BRC, AAT និង JRS មិនមានតួនាទីផ្ទាល់ណាមួយនៅក្នុងការធានាឯកជនដែលផ្តល់ដោយរដ្ឋាភិបាលផ្សេងៗគ្នានៅជុំវិញពិភពលោក។ វាអាស្រ័យលើច្បាប់អន្តោប្រវេសន៍នៃប្រទេសនីមួយៗ។

- សូមបញ្ជូនពាក្យស្នើសុំការធានាឯកជនរបស់អ្នក និងច្បាប់កូពីនៃកាតយូអិនទៅកាន់ស្ថានទូតដែលពាក់ព័ន្ធ ឬអាជ្ញាធរអន្តោប្រវេសន៍ដោយផ្ទាល់ ព្រមជាមួយនឹងសំណើស្នើអោយអាជ្ញាធរអន្តោប្រវេសន៍សុំការបញ្ជាក់ពី ស្ថានភាពនៃការធានាជនភៀសខ្លួន។

### សំណុំរឿងរបស់ខ្ញុំគឺនៅមានសុពលភាព/នៅដំណើរការ ក្នុងអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ហើយខ្ញុំចង់វិលត្រលប់ទៅប្រទេសដើមកំណើតវិញ។

### តើខ្ញុំគួរទាក់ទងអ្នកណា ?

សូមចំណាំថា ការធ្វើមាតុភូមិនិវត្តន៍តាមរយៈអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) គឺសម្រាប់តែសំណុំរឿងដែលនៅមានសុពលភាពតែប៉ុណ្ណោះ។ សូមទំនាក់ទំនងអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) សម្រាប់ព័ត៌មានលម្អិត: លេខទូរស័ព្ទការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន:

(+៦៦) ២-២៨៨-២៣៣០ និង
(+៦៦) ២-២៨៨-២៥២៩ (ក្នុងម៉ោងធ្វើការ)
អ៊ីមែល: THABA@unhcr.org

### ខ្ញុំបានរៀបចំការធានាឯកជនឬការតាំងទីលំនៅថ្មីរួចរាល់ហើយៗ គ្រាន់តែត្រូវការកាតជនភៀសខ្លួនដែលទទួលស្គាល់ដោយអង្គការ **UNHCR - តើ UNHCR** អាចចេញកាត្តនេះអោយខ្ញុំបានទេ ?

- អ្នកនៅតែត្រូវទាក់ទង នឹងត្រូវឆ្លងកាត់ដំណើរការនៃការកំណត់ស្ថានភាពជនភៀសខ្លួន (RSD) របស់ UNHCR ដដែល ។

- រាល់កូនក្តីរបស់ UNHCR ទាំងអស់នឹងទទួលបានកាត្តនេះ នៅក្រោយពេលចុះឈ្មោះ និងស្របតាមដំណើរការទាំងស្រុង។ ការត្រូវអស់សុពលភាព និងត្រូវប្រគល់សងគេវិញនៅពេលសំណុំរឿងត្រូវបានបិទ។

asylum access THAILAND

# B មជ្ឈមណ្ឌលឃុំឃាំងជនអន្តោប្រវេសន៍ (អាយឌីស៊ី)



## ១. តើ UNHCR នឹងដំណើរការសំណុំរឿងរបស់ខ្ញុំយ៉ាងដូចម្តេច ប្រសិនបើខ្ញុំនៅក្នុង IDC?

- អង្គការ UNHCR នៅតែបន្តសំណុំរឿងរបស់អ្នកតទៅទៀត ទោះបីអ្នកស្ថិតនៅក្នុង IDC ក៏ដោយ។ ត្រូវប្រាកដថា មានមន្ត្រី UNHCR ម្នាក់ដឹងថាមានអ្នកនៅទីនោះទេ។

## ២. តើមានជម្រើសប៉ុន្មានសម្រាប់ខ្ញុំ ដើម្បីអោយគេដោះលែងពីអាយឌីស៊ី ហើយតើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ?

- អាយឌីស៊ីគឺ គ្រប់គ្រងដោយរដ្ឋាភិបាលថៃ។ UNHCR មិនមានការទទួលខុសត្រូវលើការការសម្រេចក្នុងអាយឌីស៊ីឡើយ។ កាលពីមុនអង្គការ UNHCR បានចរចាអោយដោះលែងកូនក្តីដែល ជាពិសេសនោះគឺអ្នកដែលងាយរងគ្រោះ។ ឧ. អ្នកម្តាយទាំងឡាយ ដែលមានកូន ឬអ្នកដែលមានជំងឺធ្ងន់ធ្ងរ។
- ច្បាប់អន្តោប្រវេសន៍, ព.ស ២៥២២ (១៩៧៩) មិនបានកំណត់រយៈពេលអតិបរមា ចំពោះមនុស្សដែលស្ថិតនៅក្នុងការឃុំឃាំងដោយរង់ចាំការនិរទេសត្រលប់ទៅវិញនោះទេ។
- បន្ទាប់ពីរដ្ឋាភិបាលថៃបានចុះហត្ថលេខាលើអនុសារណៈយោគយល់ ដើម្បីបញ្ឈប់ការឃុំខ្លួនកុមារក្នុងពន្ធនាគាររួចមកនៅខែមករា ឆ្នាំ២០១៩ ម្តាយ និងកូនៗ ដែលជាកូនក្តីនោះក៏ត្រូវបានឃុំខ្លួនក្នុង អាយឌីស៊ី និងអនុញ្ញាតិអោយធានានៅក្រៅឃុំ។ ការបោះជំហានទៅមុខគឺជាផ្នែកមួយនៃកិច្ចសហការ ជាមួយអង្គការដទៃផ្សេងទៀតដែលហៅបានថា សេរីភាពសម្រាប់គ្រួសារ ដែលរៃអង្គាសថវិកាដើម្បីជួយដល់ម្តាយ/ផ្តល់សេវាថែទាំមូលដ្ឋានក្នុង អាយឌីស៊ី និងអាចដើរតួជាអ្នកធានាដល់ពួកគេ។

  លេខទំនាក់ទំនង៖ (+៦៦) ៨៩-១០៦-០២២៣ ឬ (+៦៦) ៩៦-៤០៥-៤៧៤៩
  អ៊ីមែល: stepaheadfostercare@gmail.com

## ៣. តើគោលការណ៍នៃការបង់ប្រាក់ធានាអោយនៅក្រៅឃុំគឺជាអ្វី តើខ្ញុំអាចធ្វើដោះរយរបៀបណា ?

- តាមរយៈការចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីការបញ្ចប់ការឃុំខ្លួនកុមារ, កុមារនិងម្តាយរបស់ពួកគេ (មនុស្សដែលស្ថិតក្នុងការការពារ) គឺមានសិទ្ធិទទួលបានការធានាអោយនៅក្រៅឃុំ, សូមមើលព័ត៌មានលំអិតខាងលើ។



## ៤. សេវាថែទាំសុខភាពនៅក្នុងអាយឌីស៊ី

- ការិយាល័យអន្តោប្រវេសន៍ គឺជាអ្នកទទួលខុសត្រូវ ក្នុងការថែទាំសុខភាពនៅក្នុងអាយឌីស៊ី។ មានគ្លីនិកពីរនៅក្នុងអាយឌីស៊ី។ មួយ បានដំណើរការដោយក្រសួងសុខាភិបាល (MOPH) និងមួយទៀតដំណើរការដោយ មូលនីធិ Jesuit ។ អ្នកជាប់ឃុំ ត្រូវបានណែនាំអោយទៅគ្លីនិកក្នុងអាយឌីស៊ី ដើម្បីទទួលបានការព្យាបាល។

  UNHCR មិនអាចផ្តល់ការថែទាំសុខភាពនៅក្នុងអាយឌីស៊ីបានទេ។ ក្នុងស្ថានភាពគ្រោះថ្នាក់យ៉ាងណាក៏ដោយ UNHCR នឹងមិនផ្តល់ព័ត៌មានជុំវិញប្រវត្តិនៃការព្យាបាលរបស់អ្នកទៅកាន់អាយឌីស៊ីនោះទេ បើគ្មានការយល់ព្រមពីអ្នក។ ការថែទាំធ្មេញគឺ មិនមានទេ។

asylum access THAILAND

## ៥. ការប្រឹក្សាយោបល់ផ្នែកចិត្តសាស្រ្ត នៅក្នុងអាយឌីស៊ី

- សំរាប់កូនក្តីរបស់អង្គការ UNHCR ដែលត្រូវបានឃុំឃាំងនៅក្នុងអាយឌីស៊ី។ ដែលត្រូវការការគាំទ្រ / មានចំណាប់អារម្មណ៍ផ្នែកចិត្តសាស្រ្ត សូមមេត្តាស្នើសុំដល់អង្គការ UNHCR ។ បុគ្គលិករបស់ UNHCR នឹងទាក់ទងដើម្បីសុំជំនួយសម្រាប់ការវាយតម្លៃបញ្ហាផ្លូវចិត្ត និងការប្រឹក្សាផ្នែកចិត្តសាស្រ្ត / ចិត្តវិទ្យា។
- BRC នឹងផ្តល់សេវាកម្មផ្នែកចិត្តសាស្រ្ត ក្នុងអាយឌីស៊ី នៅពេលស្នើសុំដោយ UNHCR ( អង្គការទាំងពីរធ្វើការរួមគ្នាដើម្បីផ្តល់សេវាកម្មរួមគ្នា ) ។



## ៦. តើខ្ញុំអាចទាក់ទងគ្រួសារ ឬមិត្តភក្តិរបស់ខ្ញុំដែលកំពុងរស់នៅខាងក្រៅដោយរបៀបណា ?

- ជាធម្មតាអាជ្ញាធរក្នុង IDC អនុញ្ញាតឱ្យអ្នកជាប់ឃុំ ប្រើទូរស័ព្ទក្នុងអាយឌីស៊ី ម្តងឬពីរដង ក្នុងមួយសប្តាហ៍ ប៉ុន្តែអ្នកជាប់ឃុំត្រូវទទួលខុសត្រូវចំពោះថ្លៃសេវាកម្ម។

## ៧. តើមានសាលារៀនសម្រាប់កូន ៗ របស់ខ្ញុំនៅក្នុងអាយឌីស៊ីដែរឬទេ ?



- វាមិនអាចទៅរួចទេ សម្រាប់កុមារក្នុងការទទួលបានការអប់រំជាផ្លូវការណ៍ ក្នុងខណៈពេលដែលពួកគេត្រូវបានឃុំខ្លួននៅក្នុងអាយឌីស៊ី។ ទោះយ៉ាងណាក៏ដោយ, ប្រទេសថៃបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពី ជម្រើសនៃការឃុំខ្លួនកុមារកាលខែមករាឆ្នាំ ២០១៩ ដើម្បីបញ្ចប់ការឃុំឃាំងកុមារ ( អន្តោប្រវេសន៍ ) ។

## ៨. ខ្ញុំត្រូវការនរណាម្នាក់មកសួរសុខទុក្ខខ្ញុំក្នុងអាយឌីស៊ី

- រាល់ជនបរទេសទាំងអស់ ដែលមានទិដ្ឋាការត្រឹមត្រូវ ឬជនជាតិថៃដែលមានឯកសារស្របច្បាប់មានសុពលភាព នឹងត្រូវបានស្វាគមន៍មកកាន់ន់ អាយឌីស៊ី ក្នុងអំឡុងពេលធ្វើការ ចាប់ពីម៉ោង ៨.០០-១១:៣០ ព្រឹក ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ( លើកលែងថ្ងៃឈប់សម្រាក )

## ៩. តើខ្ញុំអាចទទួលបានជំនួយផ្នែកច្បាប់ បានយ៉ាងដូចម្តេច នៅពេលដែលកំពុងជាប់ឃុំ ?



- នៅពេលដែលអ្នក មានពេលដើម្បីប្រើសេវាហៅទូរស័ព្ទលើកក្នុងអាយឌីស៊ីអ្នកត្រូវបានស្វាគមន៍ក្នុងការទំនាក់ទំនងទៅ AAT។ មេធាវីម្នាក់នឹងនិយាយជាមួយអ្នកដោយផ្ទាល់។ វាជាការល្អបំផុត ក្នុងការទាក់ទងទៅនៅថ្ងៃអង្គារ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែ។

## ១០. ខ្ញុំចង់ចុះឈ្មោះជាមួយ UNHCR ប៉ុន្តែខ្ញុំនៅក្នុង IDC ។



- សូមផ្ញើលិខិតស្នើសុំទៅ UNHCR ជាលាយលក្ខណ៍អក្សរ។ UNHCR នឹងទាក់ទង់ទៅបុគ្គលគ្រប់គ្នាវិញ សម្រាប់ដំណើរការបន្តទៀត។

## ១១. ខ្ញុំត្រូវបានគេបដិសេធ RSD ជាលើកដំបូងរបស់ខ្ញុំ ខណៈពេលដែលខ្ញុំស្ថិតក្នុងអាយឌីស៊ី។ តើខ្ញុំត្រូវធ្វើអ្វីបន្ទាប់ទៀត ?




- អ្នកមានពេល ៣០ ថ្ងៃ ដើម្បីដាក់បណ្ដឹងឧទ្ធរណ៍ទៅ UNHCR ។
- អ្នកអាចទូរស័ព្ទមក AAT ហើយស្នើសុំឱ្យយើងទៅសួរសុខទុក្ខអ្នកនៅក្នុងអាយឌីស៊ីដើម្បីធ្វើការវាយតម្លៃលើសំណុំរឿងរបស់អ្នក និងធ្វើជាតំណាងក្ដីអោយអ្នកបាន - មេធាវី AAT ត្រូវបានអនុញ្ញាតឱ្យចូលក្នុង IDC ដើម្បីធ្វើជាតំណាងឱ្យកូនក្ដីទាំង អ្នកដាក់ពាក្យដំបូង និងអ្នកប្ដឹងឧទ្ធរណ៍។ សម្រាប់បណ្ដឹងឧទ្ធរណ៍ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការដែលយើងត្រូវទទួលបាននូវលិខិតជូនដំណឹងនៃការបដិសេធរបស់ UNHCR មួយច្បាប់ ឱ្យបានឆាប់តាម ដែលអាចធ្វើទៅបានបន្ទាប់ពីអ្នកបានទទួលវា។

## ១២. UNHCR បានបិទរឿងក្ដីរបស់ខ្ញុំខណៈពេលដែលខ្ញុំស្ថិតនៅក្នុង IDC ។

- ការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត - សូមមើលប្រធានបទស្ដីពីការធ្វើមាតុភូមិនិវត្តន៍ដោយស្ម័គ្រចិត្ត ហើយទាក់ទងអង្គការ IOM។
- ទាក់ទងទូរស័ព្ទទៅមេធាវី AAT ហើយពួកគេអាចណែនាំអ្នកអំពីជម្រើសផ្សេងៗ រួមទាំងការវាយតម្លៃផ្លូវច្បាប់ អំពីលទ្ធភាពនៃការសុំបើកសំណុំរឿងរបស់អ្នកម្ដងទៀត និងត្រូវបន្តដោយរបៀបណា ប្រសិនបើនោះជាបំណងប្រាថ្នារបស់អ្នក។
- ការបញ្ជូនខ្លួន - ថ្លៃនៃការបញ្ជូនខ្លួននឹងត្រូវទទួលខុសត្រូវដោយបុគ្គលដែលត្រូវគេបញ្ជូននោះ។ ទោះបីជាអ្នកជាប់ឃុំឃាំងនៅក្នុង IDC បានបង់លុយថ្លៃផាកពិន័យអោយពួកគេរួចហើយក៏ដោយ ក៏ពួកគេនឹងត្រូវចំណាយសំរាប់ថ្លៃសំបុត្រយន្តហោះនិងសេវារដ្ឋបាលផ្សេងៗទៀតដែរ។

## ១៣. UNHCR បានទទួលស្គាល់ខ្ញុំជាជនភៀសខ្លួនហើយខ្ញុំស្ថិតនៅក្នុង IDC

- ជាអកុសល,ទោះបីជាអ្នកជាជនភៀសខ្លួនដែលត្រូវបានគេទទួលស្គាល់ក៏ដោយ អ្នកនៅតែត្រូវជាប់ឃុំឃាំងនៅក្នុង IDC បានដដែល ពីព្រោះប្រទេសថៃមិនបានចុះហត្ថលេខាលើអនុសញ្ញាជនភៀសខ្លួនឆ្នាំ ១៩៥១ នោះទេ។ ព័ត៌មានខាងក្រោមនេះ, ទោះបីមានកាត UNHCR ក៏ដោយ ក៏អ្នកមិនត្រូវបានអនុញ្ញាតឱ្យរស់នៅក្នុងប្រទេសថៃដោយស្របច្បាប់ដែរ។



asylum access THAILAND

# ៣

# ការការពារ និងសុវត្ថិភាព

asylum access THAILAND

# ការការពារ និងសុវត្ថិភាព



១. តើអ្នកត្រូវធ្វើដូចម្តេច ប្រសិនបើអ្នករងការគំរាមកំហែង ឬមានហានិភ័យណាមួយនៅក្នុងអគារផ្ទះល្វែងរបស់អ្នក ឬនៅក្នុងសហគមន៍របស់អ្នកឬសហគមន៍រួមគ្នាជាមួយជនជាតិថៃ ?

សម្រាប់ករណីអាសន្ន, សូមទូរស័ព្ទទៅ UNHCR ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប្រសិនបើអ្នកមើលឃើញហានិភ័យ / ការគំរាមកំហែងហើយនោះ

UNHCR ក៏មានផ្តល់សេវាពិគ្រោះយោបល់អំពីការការពារសុវត្ថិភាព នៅរៀងរាល់ថ្ងៃអង្គារនៅ BRC ចាប់ពីម៉ោង ០៩:០០ ដល់ ១៦:៣០ សម្រាប់ ២០ សំណុំរឿងក្នុងមួយថ្ងៃ ដោយអាស្រ័យការណាត់ជួបជាមុន។ អ្នកត្រូវបានណែនាំឱ្យចុះឈ្មោះ សុំការណាត់ជួបនៅឯ BRC ដោយផ្ទាល់ដោយប្រើកាត UNHCR ដែលនៅមានសុពលភាព។ UNHCR អាចវាយតម្លៃស្ថានភាពរបស់អ្នក និងបញ្ជូនបន្តទៀតបានតាមតម្រូវការ។

រាល់បញ្ហានៃការការពារណាមួយ រួមមានបញ្ហាសន្តិសុខ, ការចាប់ខ្លួន / ការឃុំឃាំង ការព្រួយបារម្ភផ្នែកច្បាប់ ការការពារកុមារពីអំពើហឹង្សាផ្លូវភេទនិងយេនឌ័រ (SGBV) រាប់បញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសារ បញ្ហាហិរញ្ញវត្ថុ បញ្ហាសិក្សាអប់រំ ការផ្តល់កំណើត និងចេញលិខិតមរណភាព ការធ្វើទុក្ខបុកម្នេញក្នុងសហគមន៍ (ឧ. ការបង្ខំឲ្យរៀបការ ការធ្វើទុក្ខបុកម្នេញដោយសារតែទំនោរផ្លូវភេទ) និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។ UNHCR នឹងមិនផ្តល់ការប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងការសុំសិទ្ធិជាជនភៀសខ្លួន RSD និង ការតាំងទីលំនៅថ្មី RST ឡើយ។



២. តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើម្ចាស់ផ្ទះផ្តល់ដំណឹងថា ខ្ញុំត្រូវតែចាកចេញពីផ្ទះរបស់ខ្ញុំ ឬប្រសិនបើខ្ញុំត្រូវការចាកចេញដោយហេតុផលផ្សេងទៀត ប៉ុន្តែគ្មានកន្លែងណាត្រូវទៅ ?

- ក្នុងករណីមានអាសន្ន, អ្នកអាចទាក់ទងទៅ UNHCR ដែលអាចជួយសម្របសម្រួល ក្រែងទទួលបានជំនួយបន្ថែម។ ប្រសិនបើអ្នកគ្មានផ្ទះសម្បែង ឬប្រឈមនឹងហានិភ័យ ដោយភាពគ្មានផ្ទះសម្បែងព្រោះ ស្ថានភាពហិរញ្ញវត្ថុរបស់អ្នក, UNHCR មិនអាចជួយក្នុងការរកផ្ទះអោយនៅបានទេ។ ក្នុងស្ថានភាពនេះ អ្នកនឹងត្រូវបានគេណែនាំឱ្យទាក់ទងទៅសមាជិកគ្រួសារ / មិត្តភក្តិ / ព្រះវិហារដែលនៅក្នុងមូលដ្ឋាន វិហារអ៊ីស្លាម ឬវត្តអារាម ដើម្បីសុំតើពួកគេអាចជួយអ្វីបានដែរឬទេ។
- អ្នកក៏អាចទាក់ទង JRS នៅថ្ងៃដែលគេអនុញ្ញាតិអោយទៅរក - ថ្ងៃច័ន្ទ, ថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ៩:០០-១៥:៣០ ។ JRS មានការសហការជាមួយការរកផ្ទះអោយស្នាក់នៅជាលក្ខណ: បន្ទាន់ចំនួន៣ "ជម្រកស្នាក់នៅ" ស្របតាមលក្ខណៈវិនិច្ឆ័យរបស់ JRS នឹងមានកន្លែងទំនេរឬទេ។

  សូមទំនាក់ទំនងតាមរយៈអ៊ីម៉ែល៖ urp.caseworker@jrs.or.th និង cc: urp.pd@jrs.or.th ឬទូរស័ព្ទមកលេខ៖ ( +៦៦ ) ០៨៤-៤២៧-៤១៣៦ ។
- ផ្ទះដែលផ្តល់សម្រាប់ការសង្គ្រោះបន្ទាន់ ដែលដំណើរការដោយមានការចូលរួម ដើម្បីលើកកម្ពស់ស្ថានភាពស្ត្រី (APSW) - សម្រាប់ស្ត្រីនិងកុមារងាយរងគ្រោះ៖ ពួកគេមានផ្ទះបន្ទាន់មួយនៅតំបន់ដនមឿងក្នុងទីក្រុងបាងកក។ សូមទាក់ទងមកលេខ ០៨៦-៨៩៩-០៦៦០ឬទាក់ទង AAT ដើម្បីធ្វើការបញ្ជូនបន្ត ព្រោះពួកគេតម្រូវអោយមានអ្នកចេះនិយាយភាសាថៃ។

! សំខាន់: ប្រសិនបើអ្នកឃើញស្ត្រី ឬកុមារណា ដែលមានហានិភ័យដោយភាពគ្មានផ្ទះសម្បែង អ្នកផ្តល់សេវាក្នុងតំបន់មួយចំនួនប្រហែលជាអាចជួយបាន ហើយអង្គការ AAT និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនក៏អាចជួយក្នុងការបញ្ជូនសំណុំរឿងបន្តបានដែរ។ សូមផ្តល់ដំណឹងឱ្យយើងដឹង ឬសុំអោយកុមារ/ក្មេងជំទង់ទាំងនោះទាក់ទងមកកាន់ AAT ដោយខ្លួនឯង។

asylum access THAILAND



៣. តើនឹងមានអ្វីកើតឡើងចំពោះខ្ញុំ ប្រសិនបើខ្ញុំត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ?



បទឧក្រិដ្ឋ នៅក្នុងប្រទេសថៃគឺសំដៅទៅលើទង្វើ ឬសកម្មភាពណាមួយដែលប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌ។ ឧ. អំពើឃាតកម្ម អំពើប្លន់ អំពើចោរកម្ម។ ប្រសិនបើអ្នកត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ដែលមិនមែនផ្អែកលើស្ថានភាពអន្តោប្រវេសន៍របស់អ្នក ដែលជាអ្នកស្វែងរកសិទ្ធិជ្រកកោន / ជនភៀសខ្លួន ដែលមិនមានទិដ្ឋាការត្រឹមត្រូវ ( ឧ. មានលិខិតឆ្លងដែនក្លែងបន្លំ ឬសកម្មភាពខុសច្បាប់ផ្សេងទៀត )៖

- ទោះយ៉ាងណាក៏ដោយ អ្នកនឹងត្រូវទទួលការបើកសវនាការ / ការស៊ើបអង្កេតរបស់តុលាការ និងតាមនីតិវិធីត្រឹមត្រូវ។
- ជាលទ្ធផល, អ្នកអាចនឹងជាប់ពន្ធនាគារ។ UNHCR មានការឃ្លាំមើលពន្ធនាគារ។

៤. ខ្ញុំជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ។ តើខ្ញុំអាចធ្វើអ្វីបាន ?



អ្នកអាចជជែកជាមួយ UNHCR និង BRC ឬរាយការណ៍ទៅ AAT ( អ្នកដែលអាចជួយអ្នករាយការណ៍ទៅ UNHCR បាន ) ។ ការវាយតម្លៃនឹងត្រូវធ្វើឡើង និងបញ្ជូនទៅផ្នែកដែលពាក់ព័ន្ធដោយសារតែពាក់ព័ន្ធនឹង SGBV, ការបំពានលើរាងកាយ មានការមិនយល់ស្របគ្នាពីបញ្ហាផ្នែកច្បាប់ជាដើម។

មានយន្តការឆ្លើយតបចំនួនបួន ដែលត្រូវបានផ្តល់ជូនអ្នករងគ្រោះដោយ SGBV

- ជំនួយផ្នែកវេជ្ជសាស្ត្រ៖ ចំនុចបន្ថែមលើរឿងមន្ទីរពេទ្យប៉ូលីស, អ្នកអាចទាក់ទងអង្គការ BRC ផ្នែកសុខាភិបាល ដើម្បីសុំអោយមានការបញ្ជូនទៅមន្ទីរពេទ្យរដ្ឋផ្សេងទៀត ដោយផ្អែកលើការលើកឡើង និងភាពសមគួររបស់អ្នក។
- ជម្រកសង្គ្រោះបន្ទាន់៖ តាមការស្នើសុំ អ្នកនឹងត្រូវបានគេទុកអោយនៅក្នុងជម្រកសង្គ្រោះបន្ទាន់ណាមួយ ដែលអាចជាកន្លែងឯកជន ឬរដ្ឋាភិបាល។
- សេវាកម្មផ្លូវចិត្ត៖ អ្នកអាចស្នើសុំការប្រឹក្សាយោបល់ ឬការព្យាបាលផ្លូវចិត្តដើម្បីទ្រទ្រង់ដល់ការព្យាបាលនូវបទពិសោធន៍ឈឺចាប់។ ការប្រឹក្សាយោបល់ត្រូវបានផ្តល់ជូននៅ BRC ឬ JRS។
- ជំនួយផ្នែកច្បាប់៖ ប្រសិនបើអ្នកចង់ធ្វើការចោទប្រកាន់ប្រឆាំងនឹងជនល្មើស, បុគ្គលិកការពារក្តីពី UNHCR ឬអ្នកតំណាងរឿងក្តីផ្នែកច្បាប់របស់អ្នកអាច ផ្តល់ប្រឹក្សាជាលក្ខណៈវិជ្ជមាន/អវិជ្ជមានជុំវិញការសម្រេចចិត្តរបស់អ្នកបាន។ ប្រសិនបើអ្នកទទូចទាមទារដើម្បីចោទប្រកាន់នានា, UNHCR នឹងជួយសម្របសម្រួល ដោយការទាក់ទងទៅអាជ្ញាធរមានសមត្ថកិច្ច ឱ្យលើកលែងការចោទប្រកាន់បទធ្វើអន្តោប្រវេសន៍ក្នុងអំឡុងពេលដំណើរការរបស់អ្នក

៥. ខ្ញុំជាអ្នកជនរងគ្រោះពីការរំលោភបំពានផ្លូវភេទ/ការបំពារបំពានផ្នែកយេនឌ័រ/ហឹង្សា។ តើខ្ញុំអាចរាយការណ៍អំពីបញ្ហានេះនៅទីណា ហើយធ្វើការពិនិត្យកោសល្យវិច្ច័យ ( “PEP Kit” ) ?

- អ្នកអាចទូរស័ព្ទទៅ UNHCR, AAT, BRC, JRS ឬអ្នកផ្តល់សេវាផ្សេងទៀត ដើម្បីរៀបចំរបាយការណ៍បញ្ជូនទៅប៉ូលីស និងធ្វើការពិនិត្យសុខភាពរាងកាយ។ វាជារឿងដ៏សំខាន់ណាស់ ដែលអ្នកត្រូវធ្វើវាឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្នុងកំឡុងពេល៧២ម៉ោងចុងក្រោយ បន្ទាប់ពីកើតហេតុកាណ៍ SGBV ។

asylum access THAILAND

- មន្ទីរពេទ្យប៉ូលីសផ្តល់ការត្រួតពិនិត្យសុខភាព ដោយឥតគិតថ្លៃដល់អ្នកដែលនៅរងគ្រោះពី SGBV ប្រសិនបើអ្នកមានសេចក្តីជូនដំណឹង (របាយការណ៍ប៉ូលីស) ចេញដោយប៉ូលីស។ ប្រសិនបើអ្នកមិនមានសេចក្តីជូនដំណឹង/របាយការណ៍មកជាមួយទេនោះ, ការចំណាយគឺចាប់ពី ២០០០ - ៣០០០ បាត។
- ទោះយ៉ាងណាក៏ដោយ, របាយការណ៍ប៉ូលីសមិនមែនចាំបាច់ចេញមកសម្រាប់តែអ្នករងគ្រោះពីបញ្ហា SGBV ម្យ៉ាងនោះទេ។ ផ្ទុយទៅវិញវាជាសិទ្ធិមួយ។ អ្នកមើលថែជនរងគ្រោះនឹងទទួលបានការប្រឹក្សាពីប៉ូលីស ពីគុណសម្បត្តិនិងគុណវិបត្តិសម្រាប់របាយការណ៍ប៉ូលីសផងដែរ។ ដូច្នេះអ្នករងគ្រោះ ឬអ្នកមើលថែអាចធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។



៦. ខ្ញុំជាស្ត្រីម្នាក់ ហើយខ្ញុំមានអារម្មណ៍ថារងការគំរាមកំហែងពីអ្នកអ្នកជិតខាងខ្ញុំ។ តើខ្ញុំអាចធ្វើអ្វីបាន?

- ទាក់ទងទៅកាន់អង្គការ UNHCR និង BRC ។
- ទាក់ទងមេដឹកនាំសហគមន៍របស់អ្នក ឬនរណាម្នាក់ដែលអ្នកទុកចិត្ត និងជូនដំណឹងពួកគេអំពីស្ថានភាពរបស់អ្នក។

៧. តើមានជំនួយណាមួយសម្រាប់កុមារ ដែលបានមកកាន់ប្រទេសថៃដោយខ្លួនឯង ដោយគ្មានមនុស្សចាស់មកជាមួយដែរទេ?

- UNHCR គឺជាអង្គការពាក់ព័ន្ធដោយផ្ទាល់ ក្នុងការគ្រប់គ្រងសំណុំរឿងសម្រាប់កុមារ ដែលបានចូលមកប្រទេសថៃដោយមិនមានមនុស្សពេញវ័យមកជាមួយ ឬអនីតិជនដែលមិនមានអ្នករួមដំណើរមកជាមួយ (UAM)។ ប្រសិនបើអ្នកជា UAM, អ្នកអាចជូនដំណឹងដល់បុគ្គលិកផ្នែកចុះឈ្មោះនៃ UNHCR នៅពេលសម្ភាសន៍ការចុះឈ្មោះរបស់អ្នក ដើម្បីបញ្ជូនសំណុំរឿងរបស់អ្នកទៅក្រុមការងារការពារកុមាររបស់ UNHCR ដែលនឹងវាយតម្លៃស្ថានភាពរបស់អ្នក ហើយបញ្ជូនអ្នកទៅរកសេវាកម្មដែលសមរម្យ។
- JRS ផ្តល់សេវាកម្មដូចជាការប្រឹក្សាយោបល់, ផ្នែកចិត្តសាស្ត្រ, ការបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម សម្រាប់កុមារដែលរស់នៅដោយខ្លួនឯង និងមិនបានរស់នៅជាមួយឪពុកម្តាយរបស់ពួកគេ។
- BRC ផ្តល់ជូននូវសេវាកម្មដល់កុមារដែលមិនបានរួមដំណើរជាមួយអាណាព្យាបាលដូចទៅនឹងសេវាកម្មដែលកុមារភៀសខ្លួនទូទៅទទួលបានដូច្នោះដែរ។ សេវាកម្មទាំងនេះរួមមានសេវាកម្មសិក្សាអប់រំមាន ថ្នាក់ភាសាថៃ ដែលត្រូវពឹងផ្អែកខ្លាំង និងជួយសម្រួលដល់ការចុះឈ្មោះកុមារភៀសខ្លួននៅសាលារដ្ឋថៃ។



asylum access THAILAND

# ៤

# ក្រុមគ្រួសារ

# និងជីវភាពប្រចាំថ្ងៃ

asylumaccess THAILAND

# ក្រុមគ្រួសារ និងជីវភាពប្រចាំថ្ងៃ

## A លំនៅដ្ឋាន

### ១ តើខ្ញុំអាចរកផ្ទះល្វែង ឬផ្ទះដែលមានតម្លៃថោក នៅទីណា?

សូមទាក់ទងទៅសហគមន៍របស់អ្នក ថ្នាក់ដឹកនាំសហគមន៍របស់អ្នក និង/ ឬ អង្គការជួយដល់ជនភៀសខ្លួនសម្រាប់ការបញ្ជូនបន្ត និងមតិយោបល់។

### ២ តើខ្ញុំអាចចរចាជាមួយម្ចាស់ផ្ទះរបស់ខ្ញុំយ៉ាងដូចម្តេច នៅពេលដែលខ្ញុំមានបញ្ហា?

- សូមទាក់ទងថ្នាក់ដឹកនាំសហគមន៍ ឬទៅជួបមិត្តភក្តិដែលនិយាយភាសាថៃដែលនឹងអាចជួយបាន។
- ទូរស័ព្ទទៅអង្គការក្រៅរដ្ឋាភិបាលដែលជួយជនភៀសខ្លួន ហើយស្នើសុំភ្ជាប់ទំនាក់ទំនងជាមួយប្រជាជននិយាយភាសាថៃ។

## B ជំនួយហិរញ្ញវត្ថុ

ត្រូវការជំនួយហិរញ្ញវត្ថុ។

តើអ្នកណាអាចជួយខ្ញុំបាន?



**សម្រាប់អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួន:**

មជ្ឈមណ្ឌលជនភៀសខ្លួនបាងកក (BRC)

- ការផ្តល់អន្តរាគមន៍ជាសាច់ប្រាក់ (CBI) ដោយមានក្របខណ្ឌក្នុងគោលបំណងជួយជនភៀសខ្លួនក្នុងទីក្រុង ដើម្បីអោយឆ្លើយតបទៅនឹងតំរូវការអាទិភាព និងស្វ័យភាពកាន់តែច្រើន។ ផ្អែក CBI ផ្អែកលើការធ្វើទស្សនកិច្ចតាមផ្ទះ និងវាយតម្លៃភាពពីងាយរងគ្រោះ។ តម្លាភាព និងភាពយុត្តិធម៌ត្រូវបានធានាដោយដៃគូជាច្រើន។ ក្រុមធ្វើការសម្រេចចិត្តដោយផ្អែកលើសំណុំរឿងដែលមានឯកសារគ្រប់គ្រាន់។ អាទិភាពត្រូវបានផ្តល់ទៅឱ្យអ្នកដែលងាយរងគ្រោះបំផុត ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់, ដំណើរទស្សនកិច្ចតាមផ្ទះ, តម្រូវការទូទៅនិងការវាយតម្លៃពីភាពងាយរងគ្រោះ ដោយបុគ្គលិកជំនាញផ្នែកសង្គមកិច្ច។
  - ដោយបុគ្គលិកជំនាញផ្នែកសង្គមកិច្ច។ ១៦៧/១ ផ្លូវរ៉ាឆាដាភិសេក ៣៦ កែងផ្លូវ១៩-៩, តំបន់ចាន់កាហ្សេម, ចតុចក្រ, ក្រុងបាងកក ១០៩០០
  - ទូរស័ព្ទ៖ (+៦៦) ២-៥១២-៥៦៣២-៤០ ១០១ (ច័ន្ទ - សុក្រ)

**UNHCR**

- UNHCR និង COERR-BRC គឺជាដៃគូអនុវត្តសេវាកម្មផ្នែកសង្គមកិច្ច។
- UNHCR និង COERR-BRC ផ្តល់ជំនួយហិរញ្ញវត្ថុដល់ជនភៀសខ្លួនទាំងក្នុង និងក្រៅ IDC តាមរយៈក្របខ័ណ្ឌ CBI (អន្តរាគមន៍ផ្អែកលើសាច់ប្រាក់) ។ ជំនួយមិនមែនបានដោយស្វ័យប្រវត្តិទេ ហើយនឹងត្រូវពិចារណាលើសំណុំរឿងនីមួយៗ។
- សូមពិនិត្យមើលដំបូន្មានបន្ថែមសម្រាប់ដំណើរការ CBI នៅចំនុចព័ត៌មាននៃ CBI ។



សំរាប់អ្នកស្វែងរកសិទ្ធិជ្រកកោន:

- សេវាកម្មជួយជនភៀសខ្លួននិកាយយេស៊ូអិត (JRS) កម្មវិធីជនភៀសខ្លួនក្នុងទីក្រុង (JRS-URP)
- អ្នកដែលត្រូវការជំនួយទាំងនោះ អាចអញ្ជើញទៅទាក់ទងនៅ៖ ថ្ងៃច័ន្ទ, ថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ៩:០០ - ១៥:៣០។ ជំនួយផ្នែកហិរញ្ញវត្ថុនឹងត្រូវផ្តល់ជូនអ្នកដែលត្រូវតាមលក្ខណៈវិនិច្ឆ័យរបស់ URP។

លេខទំនាក់ទំនង៖ (+៦៦) ០៨៤-៤២៧-៤១៣៦ អ៊ីម៉ែល:
urp.caseworker@jrs.or.th និង cc: urp.pd@jrs.or.th

វិថី ប៉ាហុនយ៉ូធិន៤៣, ផ្លូវរ៉ាឆាវិធី ១២, អានុស្សាវរីយ៍, តំបន់ផាយ៉ាថៃ។

# C ជីវភាព/ការចិញ្ចឹមជីវិត

### ១ តើមានអង្គការណាដែលបង្កើន / លើកកម្ពស់ដល់ឱកាសនៃការចិញ្ចឹមជីវិតសម្រាប់អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួនដែរឬទេ?

អង្គការ HOST អន្តរជាតិ និងអង្គការ AAT បានដំណើរការនូវគម្រោងជាច្រើនដោយរួមបញ្ចូលទាំង CHAMALiiN ដើម្បីលើកកម្ពស់ដល់ជីវភាពស្ត្រីជនភៀសខ្លួន។ សម្រាប់ព័ត៌មានបន្ថែម, សូមទំនាក់ទំនងមកកាន់អង្គការ AAT និងអង្គការ HOST អន្តរជាតិ។

### ២ តើការប្រកបការងារដោយគ្មានប័ណ្ណការងារនឹងមានហានិភ័យអ្វីខ្លះ?

ប្រសិនបើអ្នកធ្វើការដោយគ្មានការអនុញ្ញាត, អាចនឹងមានហានិភ័យដែលអាចត្រូវចាប់ខ្លួន, ឃុំខ្លួននៅក្នុង IDC នៅពេលក្រោយ។ នឹងអាចតម្រូវអោយបង់ប្រាក់ពិន័យ និងអាចត្រូវបញ្ជូនទៅវិញ។ វាក៏អាចឈានដល់ការចោទប្រកាន់ពីទោសឧក្រិដ្ឋផងដែរ។

### ៣ តើនឹងមានជំនួយខាងណាជួយដែរទេ ប្រសិនបើខ្ញុំពិការហើយមិនអាចធ្វើការបាននោះ?

អង្គការ BRC បានដំណើរការនូវគោលការណ៍មួយដែលហៅថា ការអន្តរាគមន៍លើបញ្ហាហិរញ្ញវត្ថុ (CBI)។ គម្រោង CBI នេះធ្វើឡើងដោយស្របតាមការវិនិច្ឆ័យក្រោយពេលចុះទៅពិនិត្យតាមផ្ទះ និងការវាយតម្លៃលើភាពដែលងាយរងគ្រោះរបស់អ្នក។
សូមទាក់ទងអង្គការ ប៊ីអាស៊ី សម្រាប់ព័ត៌មានបន្ថែម។ ប្រសិនបើអ្នកនៅមានឋានៈជាអ្នកស្វែងរកសិទ្ធិជ្រកកោននៅឡើយ សូមទាក់ទងអង្គការ ជេអារអេស ដើម្បីសុំព័ត៌មានបន្ថែម។

asylumaccess THAILAND

# D សុខភាព និងសុខទុក្ខទូទៅ

តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើខ្ញុំធ្លាក់ខ្លួនឈឺ ?



អ្នកអាចទាក់ទង UNHCR ដោយជំនួយពីមជ្ឈមណ្ឌលជនភៀសខ្លួនទីក្រុងបាងកក ដោយផ្អែកលើមូលដ្ឋាននៃសំណុំរឿងនីមួយៗ។ មជ្ឈមណ្ឌលជនភៀសខ្លួនទីក្រុងបាងកក អាចផ្តល់ជូនលោកអ្នក៖

១

- បញ្ជីរាយនាមមន្ទីរពេទ្យរដ្ឋ និងមណ្ឌលសុខភាពសាធារណៈក្នុងតំបន់របស់អ្នក ក៏ដូចជាព័ត៌មានស្តីពីជំនួយផ្នែកហិរញ្ញវត្ថុ សម្រាប់ករណីគំរាមកំហែងដល់អាយុជីវិតផងដែរ។
- ព័ត៌មានស្តីពីការចាក់ថ្នាំបង្ការ
- ដំបូន្មានចំពោះការធ្វើផែនការគ្រួសារ និងការពន្យារកំណើត
- ផ្តល់អ្នកបកប្រែម្នាក់ដល់អ្នក នៅមន្ទីរពេទ្យ រ៉ាតឆាវិធី ប៉ុន្តែត្រូវការការជូនដំណឹងជាមុនមួយថ្ងៃ រឺលើសពី
- ព័ត៌មាន និងការប្រឹក្សាអំពីជំនួយវេជ្ជបញ្ជាពេទ្យ
- ការវាយតម្លៃចិត្តសាស្ត្រ
- ការលើកកម្ពស់អនាម័យ
- ដំណើរការទៅលើសេវាកម្មថ្នាក់ជាតិ និងសេវាកម្មផ្សេងៗទៀត។

ជាទូទៅការរក្សាព្យាបាល ដែលអាចបើកប្រាក់វិញបានរួមមាន៖

- ការព្យាបាល ដែលអាចប៉ះពាល់ដល់អាយុជីវិត
- ការសង្គ្រោះបន្ទាន់ / គ្រោះថ្នាក់ដោយចៃដន្យ ( ទាល់តែនៅក្នុងស្ថានភាព ដែលប៉ះពាល់ដល់អាយុជីវិតប៉ុណ្ណោះ )
- ការថែទាំសំរាប់ការមានផ្ទៃពោះ និងការសំរាលកូនថ្មីៗ ( សម្រាប់តែកូនដំបូង ដែលកើតក្នុងប្រទេសថៃតែប៉ុណ្ណោះ )
- ការចាក់ថ្នាំបង្ការរោគ តាមគោលការណ៍ណែនាំថ្នាក់ជាតិនៅមណ្ឌលសុខភាពសាធារណៈ
- ការទទួលបាននូវការការពារ, ការធ្វើតេស្ត និងព្យាបាលមេរោគ HIV/ជំងឺអេដស៍, SGBV, ជម្ងឺរបេង និងជំងឺកាមរោគ និងជំងឺរ៉ាំរ៉ៃមួយចំនួន។

សូមទាក់ទង BRC សម្រាប់ព័ត៌មានបន្ថែម។ ក្នុងករណី បើចង់បើកថ្លៃព្យាបាលឡើងវិញ ចាំបាច់ត្រូវតែមានរបាយការណ៍ពីពេទ្យ។

ព័ត៌មានសំខាន់ សម្រាប់ការផ្តល់ជំនួយ ផ្នែកវេជ្ជសាស្ត្រពី BRC

- BRC ចង់អោយអ្នកជូនដំណឹង ដល់ពួកគេមុនពេលទៅមន្ទីរពេទ្យ។
- សូមទូរស័ព្ទមក BRC តាមទូរស័ព្ទលេខ ០២ ៥១២-៥៦៣២-៤, ១០៨ ក្នុងអំឡុងពេលធ្វើការ។
- ចំពោះបញ្ហាអាសន្នក្រៅពីម៉ោងធ្វើការ, សូមទាក់ទងមកលេខទូរស័ព្ទទាន់ហេតុការណ៍របស់ពួកគេតាមរយៈលេខ ០៨ ៦០១០ ៤១១៧ ដែលដំណើរការជារៀងរាល់ថ្ងៃចាប់ពីម៉ោង ០៧:០០-២៣:០០ ដើម្បីផ្តល់ការណែនាំអំពីស្ថានភាពបន្ទាន់ណាមួយ ( មានសេវាកម្មបកប្រែភាសា ចាប់ពីម៉ោង ០៩:០០-១៦:០០ រសៀលសម្រាប់ថ្ងៃធ្វើការប៉ុណ្ណោះ ) ។

ម៉្យាងទៀត អ្នកក៏អាចទៅរកមូលនិធិ ធីធី និងគ្លីនិកស៊ុកសាឡាណាណាក។ មូលនិធិធីធីមាន បើកគ្លីនិកឥតគិតថ្លៃមួយ ដែលដំណើរការជាប្រចាំរៀងរាល់ថ្ងៃអាទិត្យចុងក្រោយនៃខែ ចាប់ពីម៉ោង ០៩:០០-១៥:០០ ទល់មុខសួនហ្លួង រ.៩ ( សួនច្បារ ហ្លួងរាមា៩ ) ។ពួកគេផ្តល់ជូននូវ៖

- ថ្នាំសង្កូវ, ការចាក់វ៉ាក់សាំងសម្រាប់កុមារអាយុក្រោម ៥ ឆ្នាំ
- ការព្យាបាលធ្មេញសម្រាប់ក្មេងអាយុក្រោម ១៨ ឆ្នាំ ( លើសពី ២-៣ ដងក្នុងមួយឆ្នាំ )
- ឡានកៅអី២ជួរ ដឹកអ្នកដំណើរឥតគិតថ្លៃពីស្ថានីយ៍រថភ្លើង ឧត្តមស៊ុក ( ស្ថានីយ៍រថភ្លើងអាកាស ) ប៉ុន្តែវាទាល់តែគេទំនេរដែរ
- ថ្នាំសង្កូវដោយឥតគិតថ្លៃ
- ការធ្វើតេស្តឈាម និងមន្ទីរពិសោធន៍ទូទៅ
- គ្លីនិកចិត្តវិទ្យា
- ការព្យាបាលដោយចាក់ម្ជុលវិទ្យាសាស្ត្រ

asylum access THAILAND

គ្លីនិកស៊ីកសាទ្វាណាណាក់
ទូរស័ព្ទទំនាក់ទំនងទៈ (+៦៦) ២-២២៤-៨០៩៣
៣៥, ៣៧ ផ្លូវចាក់កាផេត, វ៉ាងប៊ូរ៉ាផាភិរម្យ, តំបន់ប្រាណាខន, ទីក្រុងបាងកក ១០២០០

- មានវេជ្ជបណ្ឌិតស្រី ដែលអាចនិយាយភាសាអង់គ្លេស ភាសាថៃ និងហិណ្ឌូ។
- ប្រតិបត្តិការដោយសហគមន៍ស៊ីក។
- មិនគិតថ្លៃគ្រូពេទ្យទេ ប៉ុន្តែត្រូវចំណាយ (អតិបរិមា ២០០ បាត) សម្រាប់ថ្លៃថ្នាំ

ដោយខ្លួនឯង

- ឱសថស្ថានជាច្រើនមានអ្នកនិយាយភាសាអង់គ្លេស ហើយអាចជួយអ្នកបានរហូតដល់កន្លែងបើកថ្នាំ សូម្បីតែថ្នាំអង់ទីប៊ីយោទិចក៏ដោយ។
- សូមជ្រាបថាឃីហោរបស់ថៃតែងមានតម្លៃថោកជាងរបស់បរទេស
- មន្ទីរពេទ្យរដ្ឋ និងមណ្ឌលសុខភាពសាធារណៈតែងតែមានតម្លៃថោក ជាងមន្ទីរពេទ្យឯកជន។

តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមានគ្រោះថ្នាក់ ?

២



- សូមទាក់ទងអង្គការ ប៊ីអាស៊ី ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ការព្យាបាលដែលអាចបើកចរិការិញ្ញបានរួមមាន បញ្ហាបន្ទាន់/គ្រោះថ្នាក់ដោយចៃដន្យគឺ សម្រាប់តែនៅពេលដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដល់អាយុជីវិតតែប៉ុណ្ណោះ។

តើខ្ញុំអាចទទួលបានសេវាសុខភាពផ្លូវចិត្តនៅទីណា ?

៣



- អ្នកអាចទៅដល់អង្គការ BRC ផ្នែកសុខាភិបាល ដើម្បីសុំធ្វើការបញ្ជូនបន្ត។
- ប្រសិនបើអ្នក ឬនរណាម្នាក់ត្រូវការជំនួយផ្នែកចិត្តសាស្ត្រ / ផ្លូវចិត្ត និងការតស៊ូជាមួយភាពតានតឹង សូមទៅកាន់ JRS-URP នៅថ្ងៃច័ន្ទ ឬថ្ងៃអង្គារ ឬថ្ងៃព្រហស្បតិ៍។

តើអ្នកណាអាចជួយខ្ញុំបាន ប្រសិនបើខ្ញុំមានផ្ទៃពោះ ?

៤



- សូមទាក់ទង BRC ប្រសិនបើអ្នកមានផ្ទៃពោះ ហើយត្រូវការជំនួយ។ សូមបញ្ជាក់ថា BRC នឹងរ៉ាប់រងថ្លៃចំណាយនៃការព្យាបាលមុនពេលមានផ្ទៃពោះ (មានកំណត់ត្រឹម ៥ ដង) និងការសម្រាលកូន សម្រាប់ម្តាយណាដែលមានផ្ទៃពោះលើកដំបូងបង្អស់ នៅប្រទេសថៃតែប៉ុណ្ណោះ។
- BRC ផ្តល់ការប្រឹក្សាយោបល់, ព័ត៌មាន និងជំនួយពីបញ្ហាផែនការគ្រួសារ។

៥

ខ្ញុំមិនទាន់បានចុះឈ្មោះជាមួយ UNHCR ឬសំណុំរឿងរបស់ខ្ញុំនៅ UNHCR ត្រូវបានបិទ ហើយខ្ញុំមិនអាចទទួលបានសេវា ហើយខ្ញុំក៏មិនអាចទទួលបានការថែទាំផ្នែកសុខភាពពី BRC ក៏ដូចជាទទួលជំនួយចរិកាផងដែរ។



- ព្យាយាមរកមណ្ឌលសុខភាពសាធារណៈណា ដែលនៅជិតអ្នកបំផុត ហើយចងចាំថានៅប្រទេសថៃមានថ្នាំជាច្រើនដែលមានលក់នៅតាមឱសថស្ថាននានា។
- ប្រសិនបើអ្នកកំពុងរង់ចាំការចុះឈ្មោះជាមួយ UNHCR ឬសំណុំរឿងរបស់អ្នកត្រូវបានបិទ សូមទាក់ទង BRC តាមរយៈលេខទូរស័ព្ទទាន់ហេតុការណ៍ផ្នែកសុខាភិបាល ដើម្បីសាកសួរអំពីមណ្ឌលសុខភាពសាធារណៈ/ឬមន្ទីរពេទ្យក្នុងតំបន់របស់អ្នកដូចដែលបានរៀបរាប់ខាងលើ។ កន្លែងខ្លះផ្តល់សេវាថែទាំសុខភាពត្រឹមតែ ៥០ បាតប៉ុណ្ណោះ។ អ្នកក៏នឹងត្រូវចំណាយសម្រាប់ថ្នាំដែរ។ គ្លីនិកធីជីគីជា លទ្ធភាពមួយផ្សេងទៀតសម្រាប់ជំងឺដែលមិនមានភាពអាសន្នធ្ងន់ធ្ងរ។

៦

តើខ្ញុំអាចធ្វើតេស្តរកជំងឺរបេង ឥតគិតថ្លៃនៅទីណា ?



- ចំពោះជម្ងឺរបេង និងមេរោគអេដស៍/ជម្ងឺអេដស៍, BRC នឹងទទួលខុសត្រូវថ្លៃពិនិត្យ និងព្យាបាលតាមការណែនាំរបស់វេជ្ជបណ្ឌិត សូមទាក់ទងផ្នែកសុខាភិបាល និងសេវាបញ្ជូនបន្តសម្រាប់ព័ត៌មានបន្ថែម ជារៀងរាល់ថ្ងៃ ក្នុងម៉ោងធ្វើការ។

# E ក្រុមគ្រួសារ



## 1. តើអ្នកណាអាចជួយបានប្រសិន បើខ្ញុំចង់រកសមាជិកគ្រួសារដែលបាត់ខ្លួន ?

ICRC និងកាកបាទក្រហម និងអង្គការសង្គមអឌ្ឍចន្ទក្រហម ធ្វើការរួមគ្នានៅជុំវិញពិភពលោក ដើម្បីកំណត់ទីតាំងមនុស្ស និងដាក់ពួកគេឱ្យមានទំនាក់ទំនងជាមួយគ្រួសារវិញ។ អ្នកអាចទាក់ទង AAT ដើម្បីដាក់អ្នកក្នុងការទាក់ទងជាមួយពួកគេ។

អ្នកក៏អាចទាក់ទងអង្គការនានាបានដោយផ្ទាល់ផងដែរ៖

### សមាគមកាកបាទក្រហមថៃឡង់ដ៏

- ( +៦៦ ) ២-២៥៦-៤០-៣២៦ ឬ ១៦៤៤, អ៊ីមែល: webmaster@redcross.or.th
- អង្គការសង្គមកាកបាទក្រហមថៃ, នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ, ការិយាល័យរដ្ឋបាល, អគារ Terd Prakiat 1871 ផ្លូវ Henry Dunant ទីក្រុងបាងកក ១០៣៣០

### គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC)

- ទូរស័ព្ទ៖ ( +៦៦ ) ២-២៦២-១៦៨០, អ៊ីមែល៖ ban_prot@icrc.org
- គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ, គណៈប្រតិភូប្រចាំតំបន់, ១៩១ / ៦-៨ អគារស៊ីធីអាយ, ជាន់ទី ៣០, មហាវិថីរាតឆាដា, ខ្លងតឺយ, ទីក្រុងបាងកក ១០១១០, ប្រទេសថៃ

## 2. តើខ្ញុំត្រូវដោះស្រាយយ៉ាងដូចម្តេចចំពោះការស្លាប់របស់សមាជិកគ្រួសារនៅក្នុងប្រទេសថៃ ?

សម្រាប់អ្នកដែលមានសំណុំរឿងនៅមានសុពលភាព អ្នកអាចទាក់ទង UNHCR ឬ AAT ដើម្បីទទួលបានជំនួយ និងដំបូន្មានបន្ថែមអំពីរបៀបទទួលបានលិខិតមរណភាព។ BRC ផ្តល់ការឧបត្ថម្ភលើការធ្វើបុណ្យសពដល់ជនភៀសខ្លួនដែល សំណុំរឿងគាត់នៅមានសុពលភាព ក្រោមក្របខ័ណ្ឌរបស់ផ្នែក CBI សូមទាក់ទង៖ ( +៦៦ ) ២-៥១២-៥៦៣២-៤០ EXT ១០១ ។

asylum access THAILAND

# ៥

# ការសិក្សាអប់រំ

# A ការសិក្សាអប់រំចំពោះកុមារ



## ១ ខ្ញុំចង់ចុះឈ្មោះកូនរបស់ខ្ញុំនៅសាលារដ្ឋថៃ

ប្រទេសថៃមានគោលនយោបាយអប់រំដែលគេហៅថា "ការអប់រំសំរាប់ទាំងអស់គ្នា" ដែលលើកកម្ពស់ការទទួលបាននូវការអប់រំសំរាប់កុមារទាំងអស់ ដែលរស់នៅក្នុងប្រទេសថៃ។

UNHCR (តាមរយៈដៃគូសហការរបស់ខ្លួន COERR) កំពុងផ្តល់ការអប់រំភាសាថៃថ្នាក់ ជំនួយនៅសាលា Good Shepherd Sister (GSS) សម្តៅជួយដល់កុមារដែលមានអាយុចាប់ពី ៦-១៧ ឆ្នាំ។ ថ្នាក់ទាំងនោះបើកបង្រៀនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ (លើកលែងថ្ងៃពុធ) ចន្លោះម៉ោង ១០:១៥ ដល់ម៉ោង ១៥:០០ និងមានពេលសំរាកអាហារថ្ងៃត្រង់មួយម៉ោង។

BRC ក៏ជួយសំរួលដល់ការចុះឈ្មោះចូលរៀនរបស់កុមារទៅកាន់សាលារដ្ឋថៃ និងឯកជន ក៏ដូចជាសាលាអន្តរជាតិនានា ដែលមានការទទួលស្គាល់ជាផ្លូវការទាំងកម្រិតបឋមនិងមធ្យមសិក្សា។ ជំនួយនឹងត្រូវផ្តល់ជូនតាមលទ្ធភាពដែលអាចទទួលយកបាន និងស្របតាមបទដ្ឋាននៃជំនួយសម្រាប់ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន។ ក្រៅពីនេះ BRC ក៏ផ្តល់ការប្រឹក្សា និងការតំរង់ទិសដល់ឪពុកម្តាយ និងសិស្សានុសិស្សផងដែរ។

សម្រាប់ការចុះឈ្មោះ និងព័ត៌មានបន្ថែម, សូមទាក់ទងអង្គភាពសិក្សាអប់រំនៅ BRC តាមលេខ (+ ៦៦) ២-៥១២-៥៦៣២ EXT ៣០៨ ឬ ៣០៩ ។

## ២ តើកូន ៗ របស់ខ្ញុំនឹងទទួលបានវិញ្ញាបនប័ត្របន្ទាប់ពីបញ្ចប់ការសិក្សាដែរឬទេ?



អត់ទេ, មិនមានឯកសារផ្លូវការណាមួយទេ បន្ទាប់ពីបញ្ចប់ការសិក្សានៅពេលនេះ សម្រាប់កម្មវិធីសិក្សាបម្រុងក្នុងសាលាថៃលើប្រទេសថៃ។ យ៉ាងណាក៏ដោយ, អ្នកដែលសិក្សានៅសាលារដ្ឋថៃ (ត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ) នឹងទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សានៅពេលបញ្ចប់ការសិក្សា។



## ៣ តើខ្ញុំត្រូវធ្វើដូចម្តេចប្រសិនបើខ្ញុំចង់អោយកូន ៗ ខ្ញុំបង្កើនជំនាញភាសាអង់គ្លេសរបស់ពួកគេ?

មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ឬអង្គការផ្សេង ៗ ទៀត ដែលផ្តល់ជូននូវវគ្គសិក្សាភាសាអង់គ្លេស។

asylum access THAILAND

# B ការអប់រំក្រៅផ្លូវការ

## តើមានវិធីផ្សេងដើម្បីអប់រំកូន ៗ របស់ខ្ញុំទេ ?

មានអង្គការមួយចំនួន ដែលមានគោលបំណងគាំទ្រ ការអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈដល់អ្នកស្វែងរកសិទ្ធិជ្រកកោននិងជនភៀសខ្លួន។ អ្នកអាចរកពីក្នុងបញ្ជីខាងក្រោម៖

### ផ្ទះបាយ Courageous

- សូមទាក់ទងទៅអងការជាមុនដើម្បីរកកន្លែងទំនេរ។
- ក្រុមដែលជាគោលដៅ៖ ថ្នាក់សំរាប់កុមារ (អាយុពី ៣ ទៅ ៦ ឆ្នាំ) ម៉ោង១០:០០ ដល់ម៉ោង១២:០០ រៀងរាល់ថ្ងៃច័ន្ទ, ថ្ងៃពុធនិងថ្ងៃសុក្រ
- ថ្នាក់រៀនសម្រាប់ក្មេងជំទង់ (អាយុ ១១ ដល់ ១៧ឆ្នាំ) រៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង១០:០០ ដល់ ម៉ោង១៥:០០
- គ្រួសារជនភៀសខ្លួនណាដែលរស់នៅសាផានម៉ៃ ត្រូវបានស្វាគមន៍ឱ្យចូលរួម។
- ព័ត៌មានលម្អិតទំនាក់ទំនង៖ តំបន់សាផានម៉ៃ, http://courageouskitchen.org

### សាលាភាសា Good Shepherd Sister

- ក្រុមដែលជាគោលដៅ: កុមារចាប់ពីថ្នាក់មត្តេយ្យដល់អាយុ ១៧ ឆ្នាំនិងមនុស្សពេញវ័យ។
- កុមារអាចសិក្សាភាសាថៃ ភាសាអង់គ្លេស សិក្សាសង្គម និងគណិតវិទ្យា។
- ព័ត៌មានលម្អិតទំនាក់ទំនង៖ (+៦៦) ២-២៤៥-០៤៥៧, អ៊ីមែល៖ info@goodshepherdbangkok.com, ៤១២៨/១ ផ្លូវឌិនឌែង
- www.goodshepherdbangkok.com
- ម៉ោងធ្វើការ: ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង ០៩:០០-១៦:០០

### Friendship Bridge (ព្រះវិហារបាប់ទីស នៅបាងចាក)

- មជ្ឈមណ្ឌលភាសាអង់គ្លេស Friendship Bridge គឺជាកន្លែងល្អមួយដើម្បីរៀនភាសាអង់គ្លេសដោយឥតគិតថ្លៃ។
- ថ្នាក់រៀនទាំងនោះត្រូវបានបើកបង្រៀនរាលសប្តាហ៍ នៅថ្ងៃសុក្រនិងថ្ងៃសៅរ៍ចាប់ពីម៉ោង ១៨:០០-១៩:៣០ និងនៅថ្ងៃអាទិត្យចាប់ពីម៉ោង ១០:០០-១១:០០ ។
- មេរៀនទាំងអស់ត្រូវបញ្ចូលព្រះគម្ពីរផងដែរ។
- ព័ត៌មានលម្អិតទំនាក់ទំនង៖ (+៦៦) ២-៧៤៦-១៥០២, អ៊ីម៉ែល bjbangkok@gmail.com, Sukhumvit ១០១/១, ឃ្វេងបាងចាក, តំបន់ប្រាខាណូង, ទីក្រុងបាងកក ១០២៦០
- www.facebook.com/pages/Bangjak-Batist-Church/380957921958712

# C ការសិក្សាអប់រំចំពោះមនុស្សពេញវ័យ

## ខ្ញុំចង់រៀនភាសាអង់គ្លេស តើខ្ញុំអាចទៅរៀនភាសាអង់គ្លេសដោយឥតគិតថ្លៃនៅឯណា ?

### មជ្ឈមណ្ឌលជនភៀសខ្លួនទីក្រុងបាងកក

- ពត៌មានលំអិតទំនាក់ទំនង៖ ១៦៧/១ វិថីរាតធាដាភិសែក ៣៦ កែងផ្លូវ ១៩-៩, ចាន់កាហ្សែម, ចតុចក្រ, ក្រុងបាងកក ១០៩០០
- ទូរស័ព្ទ (+៦៦) ២-៥១២-៥៦៣២-៤ EXT ១០៨

### ព្រះវិហារគ្រិស្ទ Creative Life Foundation

- ពត៌មានលំអិតទំនាក់ទំនង៖ ១៧០/២៣ ផ្លូវ ប្រាតិនិត, ស្វងត្ន, ធុងមហាមេឃ, ហ្សាថន, ក្រុងបាងកក, ថៃឡង់ដ៏ ១០១២០
- ទូរស័ព្ទ (+៦៦) ២-៦៧៩-៣១៨០
- www.creativelifefoundation.com
- www.facebook.com/creativelifefoundation/

asylum access THAILAND

# តើខ្ញុំមានជម្រើសអ្វីខ្លះសម្រាប់កម្មវិធីឧត្តមសិក្សា / សាកលវិទ្យាល័យឬប្រព័ន្ធអ៊ីនធឺណេតផ្សេងទៀត ?

### Future Learn (www.futurelearn.com)

- វគ្គសិក្សាតាមអ៊ិនធរណេតឥតគិតថ្លៃរាប់រយវគ្គពីសាកលវិទ្យាល័យកំពូល ៗ និងអង្គការជំនាញៗ។

### open2study (www.open2study.com)

- www.open2study.com - គឺជាវេទិកាតាមអ៊ិនធឺរណែតដែលផ្តល់នូវវគ្គសិក្សាផ្សេងៗគ្នា។
- វគ្គសិក្សាទាំងអស់មិនមែនសុទ្ធតែមិនគិតថ្លៃទាំងអស់ទេ សូមពិនិត្យមើលនៅពេលដែលអ្នកចុះឈ្មោះ។
- អ្នកនឹងទទួលបានវិញ្ញាបនប័ត្រនៃការបញ្ចប់ការសិក្សាដែលអ្នកអាចបន្ថែមទៅក្នុងជីវប្រវត្តិរបស់អ្នកបាន (CV)។
- វគ្គសិក្សាទាំងនេះមិនអាចប្រៀបផ្ទឹមនឹងសញ្ញាបត្របានទេ

### University of the People (UoPeople) (www.uopeople.edu)

- UoPeople គឺជា សាកលវិទ្យាល័យដំបូងដែលមិនគិតថ្លៃសិក្សា និងត្រូវបានទទួលស្គាល់ជាសាកលតាមអ៊ិនធឺរណែត។ បង្កើតឡើងដើម្បីអោយទទួលបាននូវការសិក្សាកម្រិតខ្ពស់, UoPeople ត្រូវបានបង្កើតឡើង ដើម្បីជួយដល់និស្សិតដែលបញ្ចប់ការសិក្សានៅវិទ្យាល័យ ដែលមានលក្ខណ: សម្បត្តិគ្រប់គ្រាន់ ដើម្បីយកឈ្នះលើបញ្ហាហិរញ្ញវត្ថុ, ភូមិសាស្ត្រ, នយោបាយ និងឧបសគ្គផ្ទាល់ខ្លួនដែលបង្អាក់ពួកគេពីការសិក្សានៅមហាវិទ្យាល័យ។
- ដើម្បីមានសិទ្ធិចូលរៀនថ្នាក់បរិញ្ញាបត្ររងឬបរិញ្ញាបត្រជាន់ខ្ពស់នៅមហាវិទ្យាល័យ UoPeople បេក្ខភាពត្រូវមានអាយុយ៉ាងតិច ១៨ ឆ្នាំ, ត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ហើយត្រូវបង្ហាញជំនាញភាសាអង់គ្លេស ( ជាមួយ TOEFL / IELTS ។ ល។
- ដើម្បីចូលរៀនកម្មវិធីសិក្សា MBA បេក្ខភាពត្រូវតែជាអ្នកជំ នាញភាសាអង់គ្លេស, ធ្លាប់ទទួលបានសញ្ញាប ត្របរិញ្ញាបត្រពីមហាវិទ្យាល័យឬសាកលវិទ្យាល័យ ដែលមានការទទួលស្គាល់ជាផ្លូវការ ត្រូវតែមានបទពិ សោធការងារពេញម៉ោងយ៉ាងតិច ២ ឆ្នាំ និងត្រូវបង្ហាញលិខិតអនុញ្ញាតិ។

### edX (www.edx.org)

- នេះជាប្រភពព័ត៌មានតាមអ៊ិនធជាភាសាអង់គ្លេស ដែលផ្តល់នូវវគ្គសិក្សាមួយចំនួនដោយឥតគិតថ្លៃ។
- ទោះយ៉ាងណាក៏ដោយ អ្នកចាំបាច់ត្រូវមានគណនីធនាគារ ឬកាតឥណទាន ដើម្បីចុះឈ្មោះចូលរៀនវគ្គសិក្សាណាដែលត្រូវបង់ប្រាក់ ឬដើម្បីទទួលបានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សា។

### Kiron Online (https://kiron.ngo)

- Kiron គឺជាអង្គការមិនមានប្រាក់ចំណូលដែលជួយដល់ជនភៀសខ្លួន, ជនអន្តោប្រវេសន៍ និងអ្នកស្វែងរកសិទ្ធិជ្រកកោនឱ្យទទួលបានការអប់រំខ្ពស់ដោយឥតគិតថ្លៃ ( ជាទូទៅវគ្គសិក្សានានាត្រូវចំណាយពេល ៣ ឆ្នាំ ) ។
- Kiron គឺមិនត្រូវបានបង់ថ្លៃទេ ប៉ុន្តែសម្រាប់តែជនភៀសខ្លួនជនភៀសខ្លួននិងអ្នកស្វែងរកសិទ្ធិជ្រកកោនតែប៉ុណ្ណោះ។
- Kiron មានគោលដៅបញ្ជូននិស្សិតរបស់ខ្លួនទៅសាកលវិទ្យាល័យជាដៃគូក្នុងចំណោមប្រទេសក្នុងទីតាំងដែលនិស្សិតទាំងនោះរស់នៅ។ ប្រសិនបើអ្នកស្ថិតនៅក្នុងប្រទេសមួយ ដែល Kiron មិនទាន់មានសាកលវិទ្យាល័យជាដៃគូនៅឡើយនោះ អ្នកនៅតែអាចដាក់ពាក្យសុំទៅសាកលវិទ្យាល័យដៃគូរបស់យើងដើម្បីបញ្ចប់សញ្ញាបត្ររបស់អ្នកបាន។

#### ព័ត៌មានសំខាន់ដែលពាក់ព័ន្ធនឹង KIRON

- Kiron គឺជាឱកាសរៀនសូត្រមួយ ប៉ុន្តែមិនមែនជាសាកលវិទ្យាល័យទេ។ Kiron មិនបានផ្តល់ជូននូវដំណើរទាំងស្រុងទៅកាន់មាហាវិទ្យាល័យ ឬសញ្ញាបត្រឡើយ។
- Kiron មិនមែនជាសាកលវិទ្យាល័យផ្លូវការមួយទេ ប៉ុន្តែជាអ្នកផ្តល់សេវាកម្មដែលជួយដល់អ្នកឱ្យចាប់ផ្តើមការសិក្សាបានជាមួយវគ្គសិក្សាតាមអ៊ិនធរណេត។
- Kiron មិនផ្តល់វគ្គសិក្សាថ្នាក់អនុបណ្ឌិតទេ។
- ការចុះឈ្មោះចូលរៀនជានិស្សិតនៅ Kiron មិនផ្តល់ឱ្យអ្នកនូវឋានៈស្របច្បាប់ក្នុងនាមជានិស្សិតនៅក្នុងប្រទេសណាមួយឡើយ។

asylum access THAILAND

### Coursera (https://refugees.coursera.org)

- Coursera ផ្តល់នូវការចូលរួមជាសកលដល់សាកលវិទ្យាល័យកំពូលៗ និងអង្គការកំពូល ៗ ដែលជាដៃគូរបស់ពួកគេ ដែលផ្តល់នូវវគ្គសិក្សាតាមអិនធរណេត។
- កម្មវិធីថ្មីដែលឧបត្ថម្ភដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងលើកលែងថ្លៃសិក្សាសំរាប់ជនភៀសខ្លួន។
- ប្រសិនបើអ្នកទទួលបានជំនួយហិរញ្ញវត្ថុ នៅក្នុងវគ្គសិក្សាជាក់លាក់ណាមួយ វានឹងត្រូវប្រើចំពោះវគ្គសិក្សានោះតែប៉ុណ្ណោះ។ អ្នកនឹងអាចចូលមើលមាតិកានៃវគ្គសិក្សាទាំងអស់ និងបញ្ចប់ការងារទាំងអស់ដែលតម្រូវអោយធ្វើ ដើម្បីទទួលបានសញ្ញាប័ត្រនៃវគ្គសិក្សា។
- អ្នកអាចចាប់យកជំនាញទំនាក់ទំនងភាសាអង់គ្លេសរបស់អ្នក ទៅកម្រិតបន្ទាប់នៅ Coursera មុនពេលអ្នកដាក់ពាក្យសុំ កម្មវិធីសិក្សាសញ្ញាប័ត្រអនឡាញឥតគិតថ្លៃណាមួយដែលមាន!
- ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោន ដែលបានចុះឈ្មោះជាមួយ UNHCR អាចទាក់ទង BRC ប្រសិនបើពួកគេចង់ចុះឈ្មោះ។ មានវគ្គសិក្សាជាច្រើនប្រភេទអាចសិក្សាបាន និងមានច្រើនភាសា



# D ជំនាញវិជ្ជាជីវៈ / វគ្គបណ្តុះបណ្តាល

## តើមានអង្គការណាមួយ ដែលបើកកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់អ្នកស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួន ហើយតើពួកគេមានជំនាញប្រភេទណាខ្លះ ?



### អាហារូបករណ៍សម្រាប់ការសាងជំនាញ (SAS) ពីសាលា Good Shepherd Sister

- ផ្តល់ជូនជំនាញភាសាអង់គ្លេស ភាសាថៃ និងជំនាញវិជ្ជាជីវៈនៅសាលា Good Shepherd (5ថ្ងៃ/សប្តាហ៍) ។
- បេក្ខភាពតម្រូវឱ្យបង្ហាញពីការមូលហេតុថាហេតុអ្វីបានគាត់មានចង់ចូលរួមក្នុងកម្មវិធីនេះ។
- បេក្ខភាពនឹងត្រូវបានផ្តល់ជាជំនួយផ្សេងៗសម្រាប់តម្រូវការលំនៅដ្ឋាន និងស្បៀងអាហារជារៀងរាល់ខែ ដោយមានលក្ខខណ្ឌតាមការចូលរួមរបស់ពួកគេ។

### ផ្ទះបាយ Kitchen

- ផ្តល់ជូនជាមេរៀនធ្វើម្ហូប ចែកចាយម្ហូបអាហារ និងជំនួយហិរញ្ញវត្ថុតិចតួច។
- ព័ត៌មានលម្អិតទំនាក់ទំនង៖ តំបន់សាផានម៉ៃ, ផ្លូវសុយុមវីត ១០១/១ http://courageouskitchen.org

### សាលា Good Shepherd Sisters

- វគ្គជំនាញមួយក្នុងចំណោមជំនាញទីផ្សារផ្សេងៗ, ភាសាថៃ, កាត់សក់, ម៉ូតសំលៀកបំពាក់សម្រាប់មនុស្សពេញវ័យ
- ព័ត៌មានលម្អិតទំនាក់ទំនង៖ (+៦៦) ២-២៤៥-០៤៥៧, អ៊ីម៉ែល៖ shepherd@cscoms.com, ៤១២៨/១ ផ្លូវឌិនឌែង

### គំរោង HOST និង AAT–CHAMALiiN

- CHAMALiiN បង្កើតឱកាស និងផ្តល់ជូននូវសម្ភារៈ សម្រាប់ផលិតនូវរបស់សិប្បកម្មស្ត្រីៗ ដែលអាចបង្ហាញពីអត្តសញ្ញាណវប្បធម៌របស់ពួកគេបាន។ គម្រោងនេះគឺដើម្បីពង្រឹងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដល់ស្ត្រីតាមរយៈការអភិវឌ្ឍជំនាញរបស់ពួកគេ, លើកកម្ពស់ការជីវភាពជំលំបាក និងទទួលបានឱកាសបង្កើតប្រាក់ចំណូល ដើម្បីពួកគេអាចក្លាយជាមនុស្សដែលពឹងផ្អែកលើខ្លួនឯង។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង HOST International និង AAT ។



asylum access THAILAND

# ៦

# អ្វីដែលគួរធ្វើ និងអ្វីមិនគួរធ្វើនៅក្នុងប្រទេសថៃ

asylum access THAILAND

# អ្វីដែលគួរធ្វើ និងអ្វីមិនគួរធ្វើនៅក្នុងប្រទេសថៃ

## អ្វីដែលគួរធ្វើ

ចូរអនុវត្តតាមច្បាប់របស់ប្រទេសថៃសម្រាប់ឥរិយាបទមួយចំនួននៅទីសាធារណៈ: ដើម្បីចៀសវាងលេសណាមួយសម្រាប់ប៉ូលីសចង់ឆែកខ្លួនយើង។ នៅប្រទេសថៃអ្នកអាចត្រូវបានឃាត់ឃ្លួននិងបង់ប្រាក់ពិន័យសម្រាប់៖

- ការដើរកំសាន្តតាមទីសាធារណៈ:
- ការទុកដាក់សំរាម
- ការជក់បារីនៅតាមទីសាធារណៈរួមមាន ការិយាល័យរដ្ឋាភិបាល, វត្តអារាម, តាមចំណតឡានក្រុង, ភោជនីយដ្ឋាន, តាមសួនឧទ្យានជាដើម។ ល។

ចូររក្សាទំនាក់ទំនងល្អជាមួយអ្នកជិតខាងនិងសហគមន៍ថៃ ( ឧ. តាមរយៈការចេះជួយយកអាសារ និងសប្បុរស ) គោរពវប្បធម៌ពួកគេ និងបទដ្ឋានផ្សេងៗទៀត។ ការដែលមានអ្នកជិតខាងល្អអាចផ្តល់ឱ្យអ្នកនូវព័ត៌មានមានប្រយោជន៍ជាច្រើន។

ចូរបន្ទាបជើងអោយនៅទាបបំផុត/ក្បាលជាចំនុចគួរគោរពបំផុត- នៅប្រទេសថៃក្បាលរបស់អ្នកត្រូវបានគេចាត់ទុកថាជាចំនុចដែលលើកដំកើងខ្ពស់និងគួរគោរព ហើយជើងរបស់អ្នកត្រូវបានគេចាត់ទុកថាចំនុចទាបបំផុត និងកខ្វក់។ វាត្រូវបានគេចាត់ទុកថាជាមនុស្សឈ្លើយបំផុត ប្រសិនបើលើកជើងរបស់អ្នកគន្លងលើក្បាលរបស់នរណាម្នាក់ ( ជាពិសេសប្រសិនបើពួកគេចាស់ជាងអ្នក ) ។ ចង្អុល ឬយកជើងប៉ះអ្វីម៉្យាងក៏ត្រូវបានគេចាត់ទុកថាជាមនុស្សឈ្លើយដែរ។ កុំភ្លេចដោះស្បែកជើងពេលចូលដល់ផ្ទះថៃ រឺតំបន់សក្ការៈ។

ត្រូវគោរពព្រះរាជា និងគ្រួសាររាជវង្ស - ប្រជាជនថៃបង្ហាញការគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះមហាក្សត្រ នឹងព្រះរាជវង្សានុវង្សរបស់ពួកគេ ហើយអ្នកគួរតែបង្ហាញនូវការគោរពដល់ពួកគេ ក្នុងនាមអ្នកជាភ្ញៀវទេសចរទៅកាន់ប្រទេសថៃជានិច្ច។ ច្បាប់ Lese Majeste - ក្រមព្រហ្មទណ្ឌរបស់ថៃបានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ១១២ ថា“ អ្នកណាដែលប្រមាថ ឬគំរាមកំហែងដល់ព្រះមហាក្សត្រមហាក្សត្រីយានី រឺអ្នករាជានុសិទ្ធិនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ ឆ្នាំទៅដប់ប្រាំបីឆ្នាំ” ។

## អ្វីដែលមិនគួរធ្វើ

កុំខឹងនិងស្រែកជំទាលជាសាធារណៈ: ឬផ្តួចផ្តើមការប្រឈមមុខ គ្នា - ជាទូទៅប្រជាជនថៃនិយាយបែបទន់ភ្លន់ នឹងជៀសវាងការប្រឈមមុខដាក់គ្នា។ សូមកុំស្រែក ឬតម្លើងសម្លេងរបស់អ្នក។

កុំដើរលើជើង ឬប្រអប់ជើងរបស់នរណាម្នាក់ - នៅក្នុងប្រទេសថៃគេចាត់ទុកថាជាទង្វើដ៏ឈ្លើយ ហើយខ្វះការគួរសមខ្លាំងណាស់ ក្នុងការកន្លងជើងដែលសណ្តូកចេញមកដោយអ្នកណាម្នាក់។ អ្នកគួរតែដើរវាងពីចុងជើងរបស់ពួកគេ។

កុំចង្អុល: ការចង្អុលទៅនរណាម្នាក់ត្រូវបានគេចាត់ទុកថាជាទង្វើមិនសមរម្យ ក្នុងវប្បធម៌នៃប្រទេសមួយចំនួនដែលក្នុងនោះក៏មានរួមបញ្ចូលទាំងប្រទេសថៃផងដែរ។ ប្រសិនបើអ្នកត្រូវចង្អុលបង្ហាញមនុស្សណាម្នាក់, ចូរធ្វើដូច្នេះដោយលើកចង្ការបស់អ្នក បែរតាមទិសដៅរបស់ពួកគេនោះទៅ។ នៅពេលធ្វើកាយវិកាឱ្យនរណាម្នាក់ឱ្យចូលមករកយើង, ចូរកុំប្រើម្រាមដៃចង្អុលត្រង់ៗដូច្នោះ។ ត្រូវធ្វើកាយវិកាដោយលារម្រាមដៃចេញមក ហើយបែរឆ្ពោះទៅដី។ ចំពោះវត្ថុ និងសត្វ, វារឹតតែគួរសមបន្ថែមទៅទៀតក្នុងការចង្អុលបង្ហាញដោយម្រាមដៃទាំងអស់របស់អ្នកជាជាងប្រើម្រាមដៃតែមួយ។

កុំព្យាយាមធ្វើដំណើរជាក្រុមធំ ៗ ហើយកុំប្រមូលផ្តុំគ្នាជាក្រុមដែលនាំអោយរំខាននៅខាងក្រៅអាគារផ្ទះរបស់អ្នក។

កុំចែកប្រាប់ស្ថានភាពជាជនភៀសខ្លួនរបស់អ្នកជាមួយអ្នកណាម្នាក់ផ្សេង។ គួរលាក់វាទុកជាការសម្ងាត់យ៉ាងតឹងរឹងចំពោះខ្លួនឯង។

កុំពិសារគ្រឿងស្រវឹង នេះជាកត្តាដ៏សំខាន់ដែលនាំឱ្យមានការរំខានដល់សាធារណៈជន។

asylum access THAILAND

# អ្វីដែលគួរធ្វើ និងអ្វីមិនគួរធ្វើនៅក្នុងប្រទេសថៃ

## អ្វីដែលគួរធ្វើ

រៀនភាសាថៃ និងបរិភោគអាហារថៃក្នុងស្រុក (អាហារថៃគឺជាធម្មតាថោកជាង និងជីវិតរបស់អ្នកនឹងមានភាពងាយស្រួលបន្តិចប្រសិនបើអ្នកមានជំនាញផ្នែកភាសា)។

យកកាត UNHCR របស់អ្នកតាមខ្លួន រឺអត្តសញ្ញាណប័ណ្ណរូបថតផ្សេងៗទៀតគ្រប់ពេលវេលា។

ចូរស្លៀកពាក់សមរម្យនៅតាមវត្តអារាម ឬវិមាននានា។ ជៀសវាងការដើរហើរតាមទីសាធារណៈ

ធ្វើការប្រឹងប្រែងរបស់អ្នកឲ្យល្អបំផុតក្នុងការថែរក្សាសុខភាព និងអនាម័យ។ ស្លៀកពាក់ និងរស់នៅស្អាត និងមានរបៀបរៀបរយ។

ត្រូវធ្វើផែនការសម្រាប់គ្រប់ស្ថានភាពទាំងអស់ រួមទាំងផែនការបម្រុង និងផែនការបម្រុងទុកមួយទៀតនៃផែនការបម្រុងមួយទៀត

## អ្វីដែលមិនគួរធ្វើ

កុំចាក់ចម្រៀងខ្លាំងៗ/ស្រែកច្រៀងនៅពេលយប់ជ្រៅក្នុងបន្ទប់របស់អ្នក។ ការឆ្មក់ចាប់ក្រុមអន្តោប្រវេសន៍ភាគច្រើនគឺ បណ្តាលមកពីការប្តឹងដោយអ្នកជិតខាង។ ដូច្នេះ, វាជាការសំខាន់ណាស់សម្រាប់កូនក្តីដើម្បីរក្សាទំនាក់ទំនងល្អជាមួយអ្នកជិតខាង និងជៀសវាងរាល់សកម្មភាពខ្លាំងៗណាមួយនៅពេលយប់។ លើសពីនេះទៀត, ម្ចាស់ផ្ទះអាចទាក់ទងអាជ្ញាធរអ្នកអនុវត្តច្បាប់ក្នុងករណីរស់នៅឈ្មៀតគ្នាក្នុងបន្ទប់មួយ។ សូមគោរពតាមវិធានការនៃម្ចាស់ផ្ទះ។

សូមកុំប្រើបណ្តាញសង្គម ឬប្រព័ន្ធអ៊ីនធឺណិតណាមួយសម្រាប់ការក្លែងបន្លំ ឬការបរិហារកេរ្តិ៍ផ្សេងៗ ព្រោះអ្នកអាចនឹងត្រូវបានចោទប្រកាន់ពីបទរំលោភលើច្បាប់ឧក្រិដ្ឋកម្មកុំព្យូទ័រឆ្នាំ ២០១៧ ។

កុំថើប ឬបង្ហាញការស្រឡាញ់រាប់អានជាសាធារណៈ។



ឧបត្ថម្ភដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក